# មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយឈ្មោះ កុយ រិទ្ធ ភេទស្រី អាយុ៥៦ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ "យោធា"**

**ស្រុកកំណើតនៅភូមិថ្មី ឃុំពោធិ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង**

**រស់នៅភូមិទួលពង្រ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ សុខ វណ្ណៈ**

**០១:៣២:២៨**

**៤០ទំព័រ**

វណ្ណៈ៖ ចឹងខ្ញុំសូមណែនាំខ្លួនម្តងទៀត ខ្ញុំឈ្មោះ សុខ វណ្ណៈ មកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយបានមកដល់ភូមិឃុំរបស់មីង គឺចង់ដឹងរឿងរ៉ាវដែលកើតឡើងពីសម័យមុនមករហូតដល់បច្ចុប្បន្នមីងណាស់ ។

រិទ្ធៈ ចាស ។

វណ្ណៈ៖ ចឹងខ្ញុំសូមសម្ភាសមីងហ្នឹងទុកជាប្រវត្តិសាស្រ្ត ដើម្បីឲ្យក្មេងៗជំនាន់ក្រោយបានដឹងបានឮមីង មិនថាអីទេ?

រិទ្ធៈ ចាស!មិនអីទេ ។

វណ្ណៈ៖ បាទ! ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះមីង មីងមានឈ្មោះអីដែរ?

រិទ្ធៈ ខ្ញុំឈ្មោះ កុយ រិទ្ធ ។

វណ្ណៈ៖ អាយុប៉ុន្មានហើយមីងសព្វថ្ងៃ?

រិទ្ធៈ ខ្ញុំអាយុ៥៦ ។

វណ្ណៈ៖ ប្តីមីងឈ្មោះអីដែរ?

រិទ្ធៈ ប្តីខ្ញុំឈ្មោះ សេក សាំង ។

វណ្ណៈ៖ គាត់អាយុប៉ុន្មានដែរ?

រិទ្ធៈ អាយុធ្វើការ៤៩ឆ្នាំអាយុពិតប្រាកដ៥៩ឆ្នាំ ។

វណ្ណៈ៖ មានកូនប៉ុន្មាននាក់ហើយឥឡូវ?

រិទ្ធៈ ខ្ញុំមានកូនបីនាក់ មានប្តីមានប្រពន្ធអស់ហើយ ។

វណ្ណៈ៖ ចឹងបីនាក់ហ្នឹងមានស្រីប៉ុន្មាន?

រិទ្ធៈ ស្រីពីរប្រុសមួយ ។

វណ្ណៈ៖ ចឹងសព្វថ្ងៃមានគ្រួសារអស់ហើយ?

រិទ្ធៈ ចាស ។

វណ្ណៈ ចឹងនៅផ្ទះជាមួយ?

រិទ្ធៈ នៅផ្ទះជាមួយពីរគ្រួសារ ។

វណ្ណៈ ចុះគ្រួសារផ្សេងទៀតទៅនៅណា?

រិទ្ធៈ គ្រួសារផ្សេងទៀតទៅនៅផ្ទះខាងនោះ ។

វណ្ណៈ ចឹងនៅក្នុងភូមិហ្នឹងដែរ?

រិទ្ធៈ ចាស ។

វណ្ណៈ ចឹងភូមិកំណើតមីងនៅណាដែរ?

រិទ្ធៈ ភូមិកំណើតនៅភូមិថ្មី ឃុំពោធិ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។

វណ្ណៈ ចឹងសព្វថ្ងៃមីងនៅភូមិអី?

រិទ្ធៈ ភូមិទួលពន្រ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

វណ្ណៈ ចឹងឪពុកបង្កើតរបស់មីងឈ្មោះអីដែរ?

រិទ្ធៈ ឪពុកម្តាយបង្កើតស្លាប់អស់ហើយដាក់ដែរ ។

វណ្ណៈ បាទ ។

រិទ្ធៈ ឪពុកខ្ញុំឈ្មោះ ចាប សាញ់ ។

វណ្ណៈ ម្តាយ?

រិទ្ធៈ ម្តាយឈ្មោះ យិន ម៉ិក ។

វណ្ណៈ គាត់ស្លាប់យូរហើយឬមួយស្លាប់ឥឡូវ?

រិទ្ធៈ គាត់ស្លាប់យូរហើយ ។

វណ្ណៈ តាំងពីជំនាន់ណាគាត់?

រិទ្ធៈ ឪពុកខ្ញុំស្លាប់ឆ្នាំប៉ុន្មានទេ ភ្លេចអស់ហើយ ។

វណ្ណៈ ស្លាប់ក្រោយ៧៩ឬមុន?

រិទ្ធៈ ក្រោយ ។

វណ្ណៈ ក្រោយ៧៩ ចឹងម្តាយ?

រិទ្ធៈ ម្តាយខ្ញុំស្លាប់ខ្ញុំយកមកនៅនេះហើយ ។

វណ្ណៈ ចឹងគាត់បានមករស់នៅនេះដែលបានស្លាប់ ។

រិទ្ធៈ ចាស! ពេលយើងផ្តាច់ខ្លួនបានទៅយកមក ។

វណ្ណៈ ចឹងបងប្អូនបង្កើតមីងមានប៉ុន្មាននាក់?

រិទ្ធៈ	បងប្អូនខ្ញុំបង្កើតមាន៣នាក់ ។

វណ្ណៈ	ប្រុសប៉ុន្មាន?

រិទ្ធៈ	ប្រុសពីរស្រីខ្ញុំម្នាក់ ។

វណ្ណៈ	ពាល់ថ្ងៃនៅរស់ទាំងអស់ឬមួយយ៉ាងម៉េច?

រិទ្ធៈ	ស្លាប់មួយជិនាន់យួនចូលហើយនៅក្នុងខ្មែរក្រហម នៅវាយយួន កាលហ្នឹងយើងមិនទាន់ស្រុះស្រួលគ្នា ។

វណ្ណៈ	ពេលឆ្នាំ១៩៧៩ហ្នឹង?

រិទ្ធៈ	ចាស ។

វណ្ណៈ	ចឹងមានន័យថា គាត់មានចលនាវាយជាមួយយួនដែរ?

រិទ្ធៈ	ចាស ។

វណ្ណៈ	ឆ្នាំណា៧៩ហ្នឹងវាយនៅខាងណា?

រិទ្ធៈ	ទេ ដូចជាឆ្នាំ៨៣-៨៤ហើយដឹង ។

វណ្ណៈ	ចឹង?

រិទ្ធៈ	ចាស ។

វណ្ណៈ	ចឹងបងទី១ឈ្មោះអី?

រិទ្ធៈ	ខ្ញុំហ្នឹងហើយ ទី២ប្រុសស្លាប់ហ្នឹង ។

វណ្ណៈ	ឈ្មោះអី?

រិទ្ធៈ	ឈ្មោះ វ៉ា កុយ វ៉ា ។

វណ្ណៈ	ចឹងគាត់បានចូលបដិវត្តដែរ?

រិទ្ធៈ	ចាស ។

វណ្ណៈ	ទី៣?

រិទ្ធៈ	ទី៣ កុយ ដិ ។

វណ្ណៈ	ចឹងពាល់ថ្ងៃនៅណា?

រិទ្ធៈ	នៅនេះដែរ ។

វណ្ណៈ	ចឹងកាលពីតូចមីងរៀនបានត្រឹមណាដែរ?

រិទ្ធៈ	ខ្ញុំរៀនបានតិចណាស់ រៀនបានត្រឹមថ្នាក់ទី១១ពីដើម១១ចាស់ ។

វណ្ណៈ	ចឹងហេតុអីបានមីងរៀនតិចដោយសារកើតមានរដ្ឋប្រហារឬដោយសារជីវភាពឬក៏យ៉ាងម៉េចមីង?

រិទ្ធៈ ទី១ ទំរាំបានចូលរៀនហ្នឹងចាស់ៗពីដើម ជីតាខ្ញុំជរាដល់ចឹងទៅខ្ញុំរៀនអាយុរៀងច្រើនដែល ហើយដល់ពេលរៀនបានឡើងថ្នាក់ចឹងទៅថ្នាក់ទី១១ហ្នឹង ទទួលរដ្ឋប្រហារសម្ដេចសីហនុ ។

វណ្ណៈ ចឹងឈប់ដោយសារមានរដ្ឋប្រហារទម្លាក់សម្ដេចសីហនុ?

រិទ្ធៈ ចាស ។

វណ្ណៈ ចឹងពេលឈប់រៀនមីងទៅណាវិញ?

រិទ្ធៈ ឈប់រៀនមកនៅជាមួយម្ដាយហ្នឹង ។

វណ្ណៈ នៅជួយធ្វើស្រែចម្ការ?

រិទ្ធៈ ចាស ។

វណ្ណៈ ចឹងកាលមីងនៅរៀនហ្នឹង គេហៅឈ្មោះសាលាបឋមសិក្សាអ្វីទៅ?

រិទ្ធៈ សាលាបឋមសិក្សាឃុំពោធិហ្នឹង ស្រុកកំពង់លែង ។

វណ្ណៈ ចឹងពេលដែលកើតមានរដ្ឋប្រហារហើយ នៅខាងស្រុកកំពង់លែងហ្នឹងមានអីផ្លាស់ប្ដូរដែលមាន ចលនាចូលព្រៃឬក៏យ៉ាងម៉េចដែរ?

រិទ្ធៈ កាលជំនាន់ហ្នឹងមាន កាលហ្នឹងគេរើសឈ្លបនារីចឹង ការរៀបចំរបស់ឃុំ ពីដើមខ្ញុំមិនសូវយល់ ដែរ ។

វណ្ណៈ បាទ ។

រិទ្ធៈ រៀបចំធ្វើឈ្លបនារីដល់ខ្ញុំទៅ ពេលហ្នឹងខ្ញុំរត់មកផ្ទះវិញ រត់មកផ្ទះវិញខាងអង្គភាពគេហ្នឹងមក តាមយកទៅវិញ តាមយកទៅវិញខ្ញុំក៏ឡើងមកតំបន់មកភូមិភាគចឹងទៅណាស់ ។

វណ្ណៈ ចឹងកាលដែលមីងចូលដំបូងហ្នឹងរដ្ឋប្រហារហើយប៉ុន្មានឆ្នាំបានមីងចូលជាឈ្លបនារី?

រិទ្ធៈ ឆ្នាំ១៩៧៣ហើយ ។

វណ្ណៈ ចឹងកាលហ្នឹងមានហេតុអីបានជាមីងចូលឬមួយមានគេបង្ខំឲ្យចូលឬយើងចង់ចូល?

រិទ្ធៈ កាលហ្នឹងដូចថាយើងវាមិនសូវយល់ មុនដំបូងគេឲ្យយើងធ្វើឈ្លបឃុំហ្នឹង ធ្វើជានិរសាគេ ដល់ធ្វើនិរសាមកចឹងកត់ឈ្មោះនៅក្នុងអង្គភាពហ្នឹងទៅ ខ្ញុំពិបាកពេករត់មកផ្ទះ ដល់ហើយគេ មកតាមយកទៅវិញ ។

វណ្ណៈ និរសាឲ្យស្រុកឬឲ្យឃុំ?

រិទ្ធៈ និរសាឲ្យឃុំ ។

វណ្ណៈ គណៈឃុំឈ្មោះអីពេលហ្នឹង?

រិទ្ធៈ ឈ្មោះ វ៉ែន ចាំតែឈ្មោះ ត្រកូលមិនចាំ ។

វណ្ណៈ ប្រុសឬស្រី?

រិទ្ធៈ ស្រី រាល់ថ្ងៃគាត់នៅតែគាត់ចាស់ដែលហើយ ។

វណ្ណៈ គាត់នៅណាវិញ?

រិទ្ធៈ គាត់នៅពោធិ នៅឃុំពោធិហ្នឹង ។

វណ្ណៈ ចឹងគាត់នៅស្រុកកំណើត?

រិទ្ធៈ ចាស ។

វណ្ណៈ ចឹងកាលហ្នឹងមីងចូលឈ្លបឃុំហើយមីងត្រឡប់មកវិញ?

រិទ្ធៈ ចាស! ហើយគេមកតាមយកទៅវិញ ។

វណ្ណៈ ពេលទៅវិញគេឲ្យមីងទៅណាទៀត?

រិទ្ធៈ គេបញ្ជូនទៅតំបន់ហើយគេបញ្ជូនទៅភូមិភាគ ។

វណ្ណៈ តំបន់ទៅតំបន់ណា?

រិទ្ធៈ តំបន់៣១ គេដាក់តំបន់៣១ កំពង់ឆ្នាំងនិងកំពង់ស្ពឺនោះ គេហៅតំបន់៣១ ។

វណ្ណៈ ចឹងខាងកំពង់ស្ពឺ៣១ដែរ?

រិទ្ធៈ ចាស! កំពង់ខាងជើងនិងកំពង់ឆ្នាំង៣១ ។

វណ្ណៈ ចឹងមីងមកដល់កន្លែងតំបន់ហ្នឹងគេឲ្យមីងធ្វើអី គេឲ្យធ្វើជាយោធាឬមួយជានិរសាទៀត?

រិទ្ធៈ ធ្វើជាយោធា ។

វណ្ណៈ កាលហ្នឹងមីងមានចេះបាញ់ទេ?

រិទ្ធៈ ចេះកាលហ្នឹងគេបង្រៀន ។

វណ្ណៈ បង្ហាត់ប្រហែលជាប៉ុន្មានខែដែរ?

រិទ្ធៈ បង្ហាត់យូរខែដែរ បង្ហាត់ហ្នឹងរៀនដោះមីងណាស់ គេធ្វើខ្សែមីនហ្នឹងគេធ្វើខ្សែវីល្លយៀវយើងហ្នឹងណាស់ ។

វណ្ណៈ បាទ ។

រិទ្ធៈ ដើម្បីយើងរៀនដោះយើងយកមីងឈើរាវខ្សែមីនអីចឹង រៀនទាំងភ័យទាំងខ្លាចហ្នឹង ការគ្រប់គ្រងកាលហ្នឹង ខ្ញុំនៅក្មេងផងកាលហ្នឹងនោះទើបអាយុ១៧ឆ្នាំទេ ។

វណ្ណៈ បាទ ។

រិទ្ធៈ ពេលចូលវាយអីចឹងយំ ខ្ញុំយំនៅក្នុងត្រង់សេហ្នឹង ។

វណ្ណៈ ចឹងពេលវាយអីយំភ័យ?

រិទ្ធៈ យំភ័យ ខ្ញុំយំរហូត ចង់មកជួបម្តាយឪពុកគេមិនឲ្យមកជួបសរសេរសំបុត្រទៅមកក៏គ្មាន ។

វណ្ណៈ ចឹងយើងចង់មកផ្ទះវិញក៏មិនបាន?

រិទ្ធៈ	មិនបានមក មកក៏រកផ្លូវមិនឃើញដែលកាលហ្នឹងនៅក្មេង ។

វណ្ណៈ	តំបន់៣១ហ្នឹងគេបញ្ជូនមកនៅម្តុំណាទៅ?

រិទ្ធៈ	គេហៅអីឈូកក្រញ៉ាសនៅខេត្តកំពង់ឆ្នាំងហ្នឹង នៅជាប់ស៊ីង ស៊ីងខដុន្តហ្នឹងនៅម្តុំហ្នឹង ។

វណ្ណៈ	ចឹងនៅជិតខដុន្តដែរ?

រិទ្ធៈ	ចាស!នៅខាងក្រាំងស្រម៉អីហ្នឹង ។

វណ្ណៈ	ចឹងមកនៅខាងក្រាំងស្រម៉?

រិទ្ធៈ	ចាស!ក្រាំងស្រម៉ ព្រៃនាងអីចឹងទៅ ។

វណ្ណៈ	ចឹងកាលហ្នឹងគណៈតំបន់មីងមានស្គាល់ឈ្មោះទេ?

រិទ្ធៈ	គណៈតំបន់ឈ្មោះ ម៉ែន ។

វណ្ណៈ	ស្រីឬប្រុស?

រិទ្ធៈ	ស្រី តែគេសម្លាប់ចោលបាត់ហើយ ។

វណ្ណៈ	គេហៅយាយម៉ែនហ្នឹង?

រិទ្ធៈ	ចាស ។

វណ្ណៈ	ចឹងយ៉ាងម៉េចបានដឹងថាគេសម្លាប់គាត់ចោល?

រិទ្ធៈ	ព្រោះអីកាលហ្នឹងគេចាប់គាត់មក គាត់អត់មានខុសអីទេ គាត់ខុសសីលធម៌ ស្រឡាញ់ប្តីគេចឹង ហើយគេឲ្យខ្ញុំយាមរាល់យប់ ។

វណ្ណៈ	មីងយាមយាយម៉ែនហ្នឹង?

រិទ្ធៈ	ចាស!ឲ្យយាមចឹង គាត់មិនបាច់យាមទេអូន បងមិនរត់ទៅណាទេ ព្រោះអីបងមិនបានក្បត់ជាតិទេ គាត់ថាចឹង គាត់គ្រាន់តែខុសសីលធម៌គាត់ថាចឹង ។

វណ្ណៈ	ចឹងគាត់ប្រាប់ត្រង់?

រិទ្ធៈ	គាត់ប្រាប់ត្រង់ហើយពេលគេចែកជាឯកសារអីចឹង ខ្ញុំអានមិនសូវរួចចឹង គាត់បង្រៀនខ្ញុំគាត់មើលឯកសារហ្នឹងឲ្យខ្ញុំស្តាប់ចឹង ឯកសារយើងជំនាន់ខ្មែរក្រហមហ្នឹង គាត់អានឲ្យខ្ញុំស្តាប់ចឹងដល់ពេលនេះទៅគេបញ្ជូនទៅភ្នំពេញគេបិទមុខចឹង បានន័យគាត់មិនរស់ទេ ខ្ញុំទៅស្រុកខ្ញុំតែងតែសួរនាំអ្នកស្គាល់ធ្លាប់នៅអង្គភាពជាមួយគ្នា គេថាមិនដែលឃើញគាត់ចឹង ។

វណ្ណៈ	ចឹងកាលគេចាប់យាយម៉ែន ចាប់ឆ្នាំណា?

រិទ្ធៈ	ចាប់ក្នុងឆ្នាំ១៩៧៦ បែកភ្នំពេញហើយ ចាប់ក្នុងឆ្នាំ៧៦ ចាប់នៅបន្ទាយលង្វែក ។

វណ្ណៈ	ចឹងចាប់នៅលង្វែក?

រិទ្ធៈ	ចាស ។

វណ្ណៈ	ចឹងបន្ទាប់យាយម៉ែន មានពីណាទៀតអនុ?

រិទ្ធៈ	ខ្ញុំអត់ដឹង ខ្ញុំដឹងថាគាត់ កាលហ្នឹងចេះខាងតំបន់ខ្ញុំនៅតិចពេក ខ្ញុំនៅភូមិភាគ កាលនៅជាមួយគាត់នៅតិច ដល់ពេលគេចាប់មកគេឲ្យខ្ញុំយាមគាត់ ។

វណ្ណៈ	ចឹងយាយម៉ែន ហ្នឹងរយៈពេលប៉ុន្មានបានគេបញ្ជូនទៅភ្នំពេញ?

រិទ្ធៈ	រយៈពេលមិនយូរទេ មិនដល់កន្លះខែផង គេបញ្ជូនទៅភ្នំពេញ ។

វណ្ណៈ	ចឹងកាលហ្នឹងបញ្ជូនពីលង្វែកទៅ?

រិទ្ធៈ	ចាស!ពីលង្វែកទៅ ។

វណ្ណៈ	ចឹងកាលហ្នឹងមកនៅតំបន់ហ្នឹងមីងនៅមិនបានយូរទេ?

រិទ្ធៈ	ចាស! គេបញ្ជូនពីហ្នឹងមកនៅភូមិភាគនិរតី ។

វណ្ណៈ	ចឹងទៅដល់និរតីទៀត?

រិទ្ធៈ	អត់ដល់ទេ តែភូមិភាគហ្នឹងភូមិភាគនិរតីកងពលទី១ ។

វណ្ណៈ	ចឹងឆ្នាំណាមីងត្រូវគេបញ្ជូនទៅកងពលទី១ ?

រិទ្ធៈ	មុនយើងចូលភ្នំពេញ ។

វណ្ណៈ	មើលឆ្នាំ៧៣ទៅតំបន់ហើយ ?

រិទ្ធៈ	ចាស ។

វណ្ណៈ	ចឹងកាលហ្នឹងនៅតំបន់បានមួយឆ្នាំទេ?

រិទ្ធៈ	កាលហ្នឹងមិនដឹងជាយ៉ាងម៉េចទេ ព្រោះអីខ្ញុំទៅនៅភូមិភាគហ្នឹងគេវាយនៅសមរភូមិ៩៩០ខាងភ្នំពេញហ្នឹង ។

វណ្ណៈ	ចឹងនៅក្នុង៧៣-៧៤ហ្នឹងទៅភូមិភាគហើយ ?

រិទ្ធៈ	ចាស ។

វណ្ណៈ	ចឹងកាលហ្នឹងកងពលទី១ប្រធានកងពលពីណាគេ?

រិទ្ធៈ	ប្រធានកងពលឈ្មោះ បងសឿង ។

វណ្ណៈ	ចឹងអនុពីណាគេ?

រិទ្ធៈ	ខ្ញុំអត់ចាំ ។

វណ្ណៈ	ចឹងចាំតែប្រធានកងពល?

រិទ្ធៈ	ចាស ។

វណ្ណៈ	ចឹងពេលទៅដល់ភូមិភាគនិរតីហ្នឹង មីងមានចាប់ផ្តើមវាយជាមួយទាហាន លន់ នល់ ហើយនៅ?

រិទ្ធៈ ចាស! វាយហើយ ។

វណ្ណៈៈ ចឹងកាលដែលវាយជាមួយទាហាន លន់ នល់ តើកម្លាំងខាងខ្មែរក្រហមមានច្រើនទេ?

រិទ្ធៈ កម្លាំងច្រើន កម្លាំងច្រើនណាស់កាលហ្នឹង ភូមិភាគគេវាយកាលហ្នឹង គេវាយប្រញាប់ចូលគ្នា ភូមិភាគនិរតីភូមិភាគមជ្ឈិមកងពល១១កងពល១៨ហ្នឹងចូលជាមួយនិរតីចឹង ដល់ចឹងកម្លាំងខ្មែរក្រហមច្រើនដែរ ។

វណ្ណៈៈ ចឹងកាលឡើងវាយហ្នឹងមីងមានបានទទួលនាទីអីទេ?

រិទ្ធៈ ខ្ញុំជាយុទ្ធនារី ។

វណ្ណៈៈ ចឹងអត់បានទទួលអីទេ?

រិទ្ធៈ អត់បានទទួលនាទីអីទេ ។

វណ្ណៈៈ ចឹងពេលដែលវាយហ្នឹងទាំងទាហាន លន់ នល់ និងទាហានខ្មែរក្រហមពេលបាញ់គ្នាហ្នឹង មីងដែលឃើញស្លាប់ផ្ទាល់ភ្នែកដែរ?

រិទ្ធៈ ឃើញតើ ទាហានខ្ញុំអត់បានឃើញទេ តែបើទាហាន លន់ នល់ មកចំត្រង់សេអីស្លាប់ឃើញ ឃើញទាហានខ្មែរក្រហមស្លាប់ចឹង ជួនណារថក្រោះរត់មកជាន់ត្រង់សេងាប់៤-៥ចឹងស្លាប់ជាន់ត្រង់សេ រថក្រោះគេហៅបាក់ខ្សែត្រៀមចឹងស្លាប់ ។

វណ្ណៈៈ ស្លាប់ខាងខ្មែរក្រហម?

រិទ្ធៈ ចាស! តែដូចថាគេឡើងវាយយកប៉ុស្តិចឹង យកបន្ទាយហ្នឹងចឹងទៅ យើងនៅក្មេងជាងគេ គេមិនអាចយកយើងទេ គេរើសអាយុច្រើនជាងយើងគេឡើងចឹងទៅ យើងនៅចាំត្រង់សេខាងក្រោយវាយបាក់មកចូលត្រង់សេ យើងនៅចាំផាវ៉ាន់អីចឹងទៅនៅត្រង់សេចឹងទៅ គេឡើងវាយគេលួនទៅចឹង ខ្ញុំគេមិនឲ្យទៅទេ ព្រោះអីនៅក្មេងជាងគេ កាលហ្នឹងអាយុ១៧ឆ្នាំ ។

វណ្ណៈៈ ចឹងអ្នកដែលឡើងទៅមុខច្រើនមានគ្រោះថ្នាក់ដែរ?

រិទ្ធៈ មានគ្រោះថ្នាក់ដែរ មានគ្រោះថ្នាក់ខ្លះដាច់បំពង់កចឹងទៅ និយាយឲ្យអស់ទៅនារីខ្លះដាច់ដោះមួយចំហៀង ។

វណ្ណៈៈ សង្គ្រាមវាយខ្មែរគ្នាឯងរហូត?

រិទ្ធៈ វាយខ្មែរគ្នាឯងរហូត កាលហ្នឹងដូចថាមិនមែនយើងយល់ស្នេហាជាតិអីណា ខ្លាចហួសពីខ្លាចហើយ ម្យ៉ាងទៀតយើងជានារីភេទខោអាវមានតែមួយកម្លេទ នៅត្រាំត្រង់សេ ជួនណាត្រង់សេទឹកចឹង ទឹកសើមគគុលកើតរមាស់កើតស្រែងខ្លួនគ្រប់គ្នា ។

វណ្ណៈៈ ចឹងវេទនា?

រិទ្ធៈ	វេទនាណាស់ តែពេលវេលាមករកឪពុកម្តាយមកមិនរួច រកផ្លូវមិនឃើញហើយមិនហ៊ានមក ទៀតខ្លាចគេចាប់ ខ្លាចគេចាប់បានបាញ់ចោលអីចឹង មិនហ៊ានមកទេ ។

វណ្ណៈ	សុខចិត្តទ្រាំកាន់កាប់ភ្លើងទៅ?

រិទ្ធៈ	ចាស ។

វណ្ណៈ	មីងគេឲ្យកាន់កាំភ្លើងអីដែរ?

រិទ្ធៈ	កាន់កាំភ្លើងអ៊ែកែង អាហ្នឹងវាស្រាល មុនដំបូងគេឲ្យកាន់កាំភ្លើងការប៊ីន ដល់ក្រោយមកគេឲ្យ កាន់អ៊ែកែវរបស់ហ្នឹងស្រាល អាការអី ព្រោះយើងនៅក្មេងគេមិនឲ្យកាន់ទេ ។

វណ្ណៈ	ចឹងមីងនៅក្នុងកងវរសេនាធំវរសេនាតូចលេខប៉ុន្មាន ។

រិទ្ធៈ	វរសេនាធំ១៣៥កងនារីតែម្តង ។

វណ្ណៈ	ចឹងនៅក្នុងវរសេនាតូចលេខប៉ុន្មានទៀត?

រិទ្ធៈ	កាលហ្នឹងគេហៅវរសេនាតូច៤១-៤២ហ្នឹង ខ្ញុំនៅ៤១ វរសេនាធំ១៣៥ ។

វណ្ណៈ	ក្នុងមួយវរសេនាធំហ្នឹងមានគ្នាប្រហែលជាប៉ុន្មាននាក់ទៅ?

រិទ្ធៈ	កាលហ្នឹងគ្រាន់ដឹងថា មួយវរសេនាតូច ដូចថាកងតូចវាមាន៣ក្រុមចឹង ហើយមួយវរសេនា តូច វាមានបីកងតូចចឹង គេហៅកងទូចកងធំចឹង ខាងវរសេនាធំវាមានបីកងតូចចឹងទៅ មើលមួយវរសេនាតូចវាមានបីកងចឹង ក្នុងមួយកងមាន១២នាក់ មានគ្រប់ចំនួនគេចឹងមាន ១១នាក់មាន១២ចឹងតែម្តង គេរៀបចំគ្រប់ៗរបស់គេ តែមេកងវរសេនារបស់ខ្ញុំគេវាយ ចោលស្លាប់បាត់ហើយ ស្លាប់តាំងពីឆ្នាំ៧៦ ។

វណ្ណៈ	ចឹងវាយចោលបាត់ហើយ?

រិទ្ធៈ	ចាស ។

វណ្ណៈ	ចឹងប្រធានវរសេនាធំមីងស្គាល់ទេ?

រិទ្ធៈ	ស្គាល់ឈ្មោះ ខុន ខ្ញុំមិនបានស្គាល់ត្រកូលគាត់ គេវាយចោល ។

វណ្ណៈ	ម៉េចបានដឹងថាគេវាយចោល?

រិទ្ធៈ	ព្រោះអីកាលហ្នឹងយើងចប់ យើងវាយភ្នំពេញដាច់ហើយគេឲ្យធ្វើស្រែ កងទ័ពកាលហ្នឹងគេឲ្យ ធ្វើស្រែ ពេលទៅស្ទូងចឹង គេទៅចាប់គាត់ពីស្រែមកគេថា គេប្រាប់គាត់ថា គាត់កើតម្រិញ នោះ គេប្រាប់ឲ្យទៅមើលម្រិញគ្រូម្រិញគេមកមើល ពេលទៅគ្នាខ្ញុំស្គាល់ៗគ្នាហ្នឹងគេថា ខុន គេចងហើយ ចងទៅគុក២៤គេហ្នឹង នៅលផ្នែកហ្នឹងមានគុក ពួកខ្ញុំទៅដល់យាមកន្លែងគុកហ្នឹង មានព្រុសម្លេងគាត់ស្រែក ក្រោយមកគាត់មានពោះធំ គាត់មានប្តីកាលហ្នឹងគេការឲ្យ គាត់ ពោះធំ ដល់ចឹងទៅឆក់ខ្សែភ្លើងកូនកើតមិនគ្រប់ខែ កើតមិនគ្រប់ខែយកកូនទៅពេទ្យទៅបាន

រយៈពេលប្រហែលជាប៉ុន្មាននាទីទេ មិនដល់កន្លះម៉ោងផងកូនហ្នឹងស្លាប់ ចឹងបានថាកំណត់គាត់ស្លាប់តែម្តង ។

វណ្ណៈ: ចឹងធ្វើទារុណកម្មទាំងអ្នកមានផ្ទៃពោះគិតទៅគ្មានសីលធម៌ទេ?

រិទ្ធៈ: អត់មានទេ កាលហ្នឹងអត់មានមែន ដូចថាយើងក្មេងតែយើងដឹងខ្លះ ដឹងថាវេទនាណាស់ពូមាត់ស្រែកច្បាស់ចែស ស្រែកឲ្យជួយ ។

វណ្ណៈ: យើងគិតមើលមនុស្សមានផ្ទៃពោះបើសិនជាប្រទេសមានច្បាប់មិនអាចធ្វើដល់ថ្នាក់ហ្នឹងទេ?

រិទ្ធៈ: ចាស!មិនដល់ថ្នាក់ហ្នឹងទេ សម្លេងគាត់ស្រែកច្បាស់ណាស់ ស្រែកឲ្យគេជួយ ស្រែកដូចថាគាត់ស្គាល់ចឹង ហើយប្តីគាត់មិនឲ្យមកជិតទេ ប្តីគាត់យកប្រពន្ធទៀតរាល់ថ្ងៃនៅអន្លង់វែង ។

វណ្ណៈ: ចឹងខុសតែគាត់ប្តីគាត់អីបានរួចខ្លួន?

រិទ្ធៈ: កាលហ្នឹងគេចោទប្រកាន់គាត់ថា គាត់មានប្តីហើយគាត់ទៅស្រឡាញ់ តារ៉ុន ប្រធានវរសេនាធំ តែការពិតខ្ញុំមិនបានដឹងដែរ កាលហ្នឹងគេចោទប្រកាន់ខុសសីលធម៌ក្បត់ប្តីចឹង តែប្តីកាលហ្នឹងអត់មានមកជិតគាត់ទេ តែកូនគេឲ្យប្តីមកគេដឹងថាកូនជាមួយប្តីគាត់ចឹង តែកូនមិនរស់កូនស្លាប់ តែប្តីឥឡូវគាត់រៀងឡប់ដែរ គាត់យកប្រពន្ធីក្រោយមែន តែគាត់រៀងបាត់សន្តិមិនគ្រប់គ្រាន់ សរសៃរប្រាសាទ យកទៀតក្នុងការរៀបចំមិនមែនយើងស្រឡាញ់ទេ មិនមែនយើងស្រឡាញ់ពីណាយកអ្នកហ្នឹងបានទេ កាលហ្នឹង ដូចថាប្រពន្ធគេសម្លាប់ចោលចឹង គេរៀបចំឲ្យគាត់យកប្រពន្ធមួយទៀតទៅ ដល់ពេលខ្ញុំមានប្តីបានខ្ញុំដឹងថា គាត់មានអារម្មណ៍អាណិតប្រពន្ធកូនគាត់ចឹង ។

វណ្ណៈ: ចឹងខ្ញុំចង់សួរបន្តទៀត ពេលមីងនៅខាងភូមិភាគនិរតីហ្នឹង ពេលមីងវាយចូលភ្នំពេញតាមច្រកណាទៅតាមផ្លូវជាតិលេខប៉ុន្មាន?

រិទ្ធៈ: កាលហ្នឹងគេហៅសមរភូមិ៩៩០ហ្នឹង គេហៅត្រង់ណាទេ កប់ស្រូវ ។

វណ្ណៈ: សមរភូមិ៩៩០?

រិទ្ធៈ: សមរភូមិ៩៩០ហ្នឹងសមរភូមិភ្នំពេញហ្នឹងហើយ ។

វណ្ណៈ: ចឹងសមរភូមិ៩៩០ហ្នឹងឈ្មោះពីណាជាអ្នកដាក់?

រិទ្ធៈ: អត់ដឹងដែរ កាលហ្នឹងអត់ដឹង ។

វណ្ណៈ: ចឹងគេហៅសមរភូមិ៩៩០?

រិទ្ធៈ: ចាស ។

វណ្ណៈ: ចឹងកាលហ្នឹងមីងវាយចូលតាមកប់ស្រូវ?

រិទ្ធៈ: ចាស!ចាំវាមិនបានអស់ម្យ៉ាងទៀតនៅក្មេង ណាមួយយូរដែលហើយ ។

វណ្ណៈ: ចឹងមឹងមានបានវាយចូលដល់ភ្នំពេញទេ?

រិទ្ធៈ: ចូលដល់តើ ។

វណ្ណៈ: ថ្ងៃទី១៧មេសាហ្នឹង?

រិទ្ធៈ: ចាស!ចូលដល់ភ្នំពេញ ។

វណ្ណៈ: ម៉ោងប៉ុន្មាន?

រិទ្ធៈ: ចូលដល់ភ្នំពេញកាលហ្នឹងនៅពេលព្រឹក មិនដឹងជាម៉ោងប៉ុន្មាន ប្រហែលជាម៉ោង៨ដឹងបើមិន ៨ម៉ោង៩ហ្នឹងហើយ ខ្ញុំទៅដល់ភ្នំពេញ ខ្ញុំជួបបងខ្ញុំជីដូនមួយហៅ បងខ្ញុំឃាត់មិនឲ្យហៅទៀត នោះ ប្រពន្ធស្ងាប់តាមមើល ឃើញកូនស្រីមួយដាក់លើរឺម៉ក គាត់អូសរឺម៉ក រឺម៉កយើងពី ក្រោយហ្នឹង ឃើញអូសរឺម៉កខ្ញុំស្រែកហៅខ្ញុំស្គាល់បងខ្ញុំច្បាស់ណាស់ ។

វណ្ណៈ: បងបង្កើត?

រិទ្ធៈ: បងជីដូនមួយ គេជម្លៀសចេញទៅមើលទៅវេទនាខ្លាំងណាស់ អត់ឃើញប្រពន្ធឃើញតែកូន ខ្ញុំស្រែកហៅទៅប្រធានកងតូចខ្ញុំមិនឲ្យទាក់ទង ដូចថាអ្នកជម្លៀសចឹងគេមិនឲ្យទាក់ទងរាក់ទាក់ អីចឹង ។

វណ្ណៈ: បាទ ។

រិទ្ធៈ: ខ្ញុំរត់ទៅហៅខ្ញុំរត់ពីហ្នឹងទៅដល់សាលាឃុំនោះ ទៅហៅបងខ្ញុំនោះ ដល់ចឹងគេស្រែកហៅមក វិញកុំ កុំឲ្យខ្ញុំទំនាក់ទំនង ។

វណ្ណៈ: ខ្លាចយើងពាក់ព័ន្ធ?

រិទ្ធៈ: ចាស!ខ្លាចពាក់ព័ន្ធតែខ្ញុំស្រណោះបង ឃើញតែក្មួយមួយអូសរឺម៉កពីក្រោយម៉ូតូទេណា អូស ម៉ូតូអត់មានសាំង មិនមែនកង់ទេ អូសរឺម៉កម៉ូតូឃើញតែកូនស្រីមួយ ។

វណ្ណៈ: គាត់អូសសំដៅមកខាងស្រុកកំណើតគាត់ឬមួយគាត់អូសទៅខាងណា?

រិទ្ធៈ: ឥឡូវហ្នឹងអត់ឃើញ ខ្ញុំទៅស្រុកកំណើតច្រើនដងហើយ ដំណើរគេជម្លៀសហើយគេសម្លាប់ គេចំរាញ់ជំនាន់ពួកក្បត់អីចឹង ប្រហែលជាគេសម្លាប់ចោលបងខ្ញុំហ្នឹង ព្រោះខ្ញុំទៅសួរមីងខ្ញុំ គាត់ថាអត់មានឃើញបាត់ឈឹងតែម្តង បាត់តាំងពីនោះរហូតដល់ឥឡូវ ។

វណ្ណៈ: ចឹងប្រពន្ធគាត់ក៏បាត់គាត់ក៏បាត់?

រិទ្ធៈ: ចាស!បាត់ទាំងអស់ ។

វណ្ណៈ: ចឹងគាត់ជាមន្ត្រីរាជការ?

រិទ្ធៈ: អត់ទេ គាត់ជាប្រជាជនរកស៊ីនៅភ្នំពេញហ្នឹង គាត់រត់ម៉ូតូរឺម៉កឌុបអីហ្នឹង គាត់អត់មានធ្វើការ អីទេ គាត់ជាប្រជាជន ។

វណ្ណៈ៖ ចឹងពេលពេលចូលដល់ភ្នំពេញហ្នឹង យើងមានតួនាទីប្រាប់ឲ្យប្រជាជនចេញឬមួយយើងបាញ់យើងដេញគាត់យ៉ាងម៉េចពេលហ្នឹង?

រិទ្ធៈ ខ្ញុំកាលហ្នឹងខ្ញុំអត់ដឹងថាគេដេញឬយ៉ាងម៉េច ព្រោះកងពលហ្នឹងហៅខ្ញុំឲ្យទៅចាំការ៉ាស់សាំង គាត់ប្រគល់ប៊ិនមួយសៀវភៅមួយ ពេលឡានដឹកប្រជាជនចេញហ្នឹងឲ្យចាក់ចុះ ឲ្យកត់ប៉ុន្មានលីតអីចឹង ដល់ចឹងយើងក្មេងហើយយើងនារីសុទ្ធសាធចឹងខ្ញុំអត់ដឹងទេ ។

វណ្ណៈ៖ ដឹងថាប្រជាជនចេញ?

រិទ្ធៈ ចាស!ចេញមកទាំងឡានៗហ្នឹង ចូលការ៉ាស់សាំងហ្នឹង គេឲ្យខ្ញុំនៅចាំហ្នឹងមាននារីបីនាក់ តែខាងកងពលហ្នឹងគាត់មានសៀវភៅមួយក្បាលប៊ិចមួយចឹងឲ្យកត់ កត់ថាឡានហ្នឹងចាក់ប៉ុន្មានលីតៗអីចឹង គ្រាន់កត់តែប៉ុណ្ណឹងទេ ឲ្យឡានចេញពីភ្នំពេញមកដឹកប្រជាជនឲ្យចាក់តែម្តង ។

វណ្ណៈ៖ សាំងនៅម្តុំណា?

រិទ្ធៈ សាំងផ្លូវកាបូលមិនដឹងជាម្តុំណាទេ វភ្លេចអស់ហើយ ។

វណ្ណៈ៖ ចឹងខាងពោធិចិនតុងអីហ្នឹង?

រិទ្ធៈ ចាស!ខ្ញុំនៅខាងពោធិចិនតុង ខ្ញុំនៅអូរបែកក្អម ។

វណ្ណៈ៖ ចឹងថ្ងៃទី១៧មេសាម៉ោង៩ហ្នឹង មីងបានចូលដល់ទីក្រុងតែម្តង?

រិទ្ធៈ ចាស!ទូមាស មានមាសក្រហមប្រាលពេញទូមាស តែបានទៅដល់តែមួយភ្លេតទេណាស់មួយភ្លេចពួកខ្ញុំគេដឹកមកវិញ ដឹកចេញមកវិញមកនៅអូរបែកក្អមហ្នឹង ។

វណ្ណៈ៖ ចឹងពេលមីងនៅដល់ឃើញមាសអីមីងចង់បានទេពេលហ្នឹង?

រិទ្ធៈ បើចង់បានក៏អត់ កាលហ្នឹងអារម្មណ៍វាអត់មានចង់បាន ។

វណ្ណៈ៖ ចឹងឃើញមានមាសក្នុងទូមាសតែម្តង?

រិទ្ធៈ ចាស!មាសឡើងក្រហមហើយអំពូលគេនៅតាមហ្នឹង ទោះបីខ្ញុំធ្លាប់ហើយប្រជាជនគាត់យួនគាត់យួនធាត់យាយហ្នឹង គាត់ដោះពីខ្សែចង្កេះគាត់ថាមួយដំឡឹងគាត់ឲ្យខ្ញុំចឹង គ្រាន់មកដល់ភ្លាមមេខ្ញុំមកដល់ដក ទោះបីខ្ញុំចង់បានក៏មិនបានដែរ គេមិនទុកចិត្តយើងតែម្តង អាហ្នឹងខ្លាចគេចាប់ ខ្លាចគេផែកមើលតាមផ្លូវ គេឃើញរបស់ហ្នឹងគេមិនទុកចិត្តយើងទេ ខ្លាចគេយកទៅវាយចោលមិនហ៊ានទេ ចង់បានៗតែខ្លាចគេចាប់បាន ។

វណ្ណៈ៖ មាសហ្នឹងនៅម្តុំណាផ្សារថ្មី?

រិទ្ធៈ អត់ទេ មាសហ្នឹងមិនដឹងត្រង់ណាទេខ្ញុំមិនសូវស្គាល់ ខ្ញុំមិនថាត្រង់ណាៗ ។

វណ្ណៈ៖ ហើយមានពីណាប្រមូលយកទេ?

រិទ្ធៈ អត់ទេ អត់ដឹងទេ ព្រោះអីខ្ញុំចូលបានតែមួយភ្លេចចឹង គេដឹកពួកខ្ញុំមកវិញមកនៅអូរបែកក្អម អូរបែកក្អមហើយបានគេឲ្យមកនៅកន្លែងវាលយន្តហោះនេះ យន្តហោះខូចៗនៅពោធិចិនតុងហ្នឹង នៅបោសសម្អាតរៀបអំបែងកែវអំបែងដបអីហ្នឹង តាមហ្នឹង ។

វណ្ណៈ: ចឹងនៅព្រលានយន្តហោះចាំចាក់សាំង?

រិទ្ធៈ អត់ទេ មិនមែនកន្លែងព្រលានយន្តហោះទេ មានកន្លែងការ៉ាស់សាំងគេតែម្តង តែមិនដឹងជាម្តុំត្រង់ណាទេ ។

វណ្ណៈ: តែផ្លូវទៅព្រលាន?

រិទ្ធៈ ចាស ។

វណ្ណៈ: ចឹងមីងចូលបានមួយភ្លេចមីងចេញមកវិញ?

រិទ្ធៈ ចាស!ចូលបានមួយភ្លេចគេបញ្ជូនមកនៅអូរបែកក្អម ដូចថាគេរៀបចំតាមកងពលអីចឹង តាមវរសេនាធំអីហ្នឹងចេញ កាលហ្នឹងស្រីៗមិនបានចូលយូរផងដកចេញមកតាមអង្គភាពទៅវរៈខ្ញុំដកចេញមកនៅតែខាងពូៗគេនៅបោសសម្អាតស្អីៗមានតែពូៗទេ ខ្ញុំមកនៅកាលហ្នឹងដូចផ្លូវអត់សូវមានផ្ទះទេ មិនដឹងត្រង់ណាវាមិនចាំ យើងមកដល់ដំបូងបានពីរបីថ្ងៃបានគេយកទៅដាក់អូរបែកក្អមទៀត ពេលគេជម្លៀសប្រជាជនចេញមកចឹង ខ្ញុំនៅកន្លែងការ៉ាស់សាំងហ្នឹងមិនសូវមានផ្ទះទេ ។

វណ្ណៈ: ចឹងមីងនៅអូរបែកក្អមរយៈពេលប៉ុន្មានទៀតបានមីងចេញមកខាងលង្វែកអីហ្នឹង?

រិទ្ធៈ ខ្ញុំនៅយូរដែរ នៅខ្ទង់នៅអូរបែកក្អមហ្នឹងគេឲ្យពួកខ្ញុំរើផ្ទះ រើយកគ្រែអីតាមផ្ទះហ្នឹង រើដឹកមកលង្វែក ខ្ញុំនៅរយៈពេលមិនដល់មួយឆ្នាំទេ រយៈហ្នឹងប៉ុន្មានខែទេ ប្រហែលជា៥ទៅ៦ខែដឹងរើយកគ្រែដឹកមកលង្វែកហ្នឹង ។

វណ្ណៈ: ចឹងបោសសម្អាតក្រុងចឹង?

រិទ្ធៈ ចាស ។

វណ្ណៈ: ចឹងនៅប្រហែលជាប៉ុន្មានខែដែរ?

រិទ្ធៈ ប្រហែលជា៤ទៅ៥ខែហ្នឹង ។

វណ្ណៈ: ចឹងពេលមកនៅលង្វែកជាប់ឬគេបញ្ជូនទៅខាងណាទៀត?

រិទ្ធៈ នៅលង្វែកហ្នឹងបានប៉ុន្មានទេ ៧៧គេបញ្ជូន មើលលង្វែកហ្នឹង ។

វណ្ណៈ: ឆ្នាំណាមកនៅលង្វែក?

រិទ្ធៈ ឆ្នាំ៧៧គេបញ្ជូនខ្ញុំមកនៅខេត្តសៀមរាប ។

វណ្ណៈ: ចឹង?

រិទ្ធៈ ចាស!គេបញ្ជូនមកទាំងកងពលតែម្ដង កងពលខ្ញុំមកដែលចិន គេដកដូរខ្លះ តាម៉ុក គាត់មកដូរ តាម៉ុក កាលហ្នឹងគេហៅតា១៥ គាត់ដកកងពលពួកខ្ញុំហ្នឹងមកនៅសៀមរាប ។

វណ្ណៈ ចឹងលង្វែកនៅធ្វើអីនៅធ្វើស្រែឬធ្វើអី?

រិទ្ធៈ នៅធ្វើស្រែ អត់មានធ្វើអីទេ កាលហ្នឹងធ្វើស្រែ ។

វណ្ណៈ ចឹងកាលមកនៅលង្វែកមានកងពលមានអីទេ?

រិទ្ធៈ មានតើ ។

វណ្ណៈ កងពលលេខប៉ុន្មានទៅ មានផ្លាស់ប្តូកងពលទេឆ្នាំ៧៥ហើយ?

រិទ្ធៈ អត់ទេ អត់មានផ្តូទេខ្ញុំនៅកងពលដដែល ។

វណ្ណៈ កងពលពីណា?

រិទ្ធៈ កងពលតាសឿង ដដែល នៅរហូតមកដល់សៀមរាបហ្នឹង ខ្ញុំនៅជាមួយគាត់រហូត តែមក ដល់សៀមរាបហ្នឹង លែងកងពលហើយដឹង ភូមិភាគទេដឹង កាលហ្នឹង ។

វណ្ណៈ ចឹងកាលហ្នឹងតាសឿង មកនៅលង្វែកដែរ?

រិទ្ធៈ ចាស!មកនៅលង្វែកមកនៅសៀមរាបគេសម្លាប់ចោលអស់ទៅ ។

វណ្ណៈ ចឹងនៅឆ្នាំ១៩៧៧គេបញ្ជូនមកខេត្តសៀបរាមវិញ?

រិទ្ធៈ ចាស!គេសម្លាប់ចោលនៅសៀមរាបហ្នឹង ។

វណ្ណៈ ចឹងតាសឿង គាត់មកដែរ?

រិទ្ធៈ គេផ្លាស់គាត់មកបានគាត់យកពួកខ្ញុំមកតាមចឹង ។

វណ្ណៈ មកសៀមរាបមានគ្នាប៉ុន្មាននាក់ដែរ?

រិទ្ធៈ មកសៀមរាបមានគ្នាតិចដែរ ប្រហែលជា១០០ទៅ២០០អីហ្នឹង អត់មានយកមកទាំងអស់ ទេ កូនប្រពន្ធគាត់មក មកនៅបានប៉ុន្មានខែទេ បានគេសម្លាប់ ។

វណ្ណៈ ចឹងតាសឿង មកគ្រប់គ្រងហ្នឹងដែរ?

រិទ្ធៈ ចាស!មកគ្រប់គ្រងនៅពេលគាត់បើកឡានគេ ខ្មែរគ្នាយើងហ្នឹងពួកគេហៅ០៩-០៨គេហៅ ភូមិភាគអីខាងក្រូចឆ្មារហ្នឹងមកស្ទាក់វាយគាត់ឡានស្លាប់ទៅ ។

វណ្ណៈ ស្លាប់ក្រោយឆ្នាំ៧៩ឬស្លាប់ពេលណា?

រិទ្ធៈ ស្លាប់ពេល... ។

វណ្ណៈ ស្លាប់ពេលវៀតណាមចូលឬស្លាប់ពេលណា?

រិទ្ធៈ ស្លាប់ពេលវៀតណាមចូល វៀតណាមចូលមិនយើងបែកបាក់រត់មក ។

វណ្ណៈ ចឹងមិនមែនស្លាប់នៅក្នុងសម័យបីឆ្នាំទេ?

រិទ្ធៈ	មិនមែនទេ កាលហ្នឹងគេថា ខាងបូព៌ានិរតី គេស្អប់ពួកនិរតីអីចឹងណាស់ កាលហ្នឹងខ្ញុំមិនបាន ដឹងថា ពីណាសម្លាប់ទេ ខ្ញុំដឹងថាគេបាញ់ឡានឆេះខ្ទិចអស់ ស្លាប់នៅក្នុងឡានតែម្តង ងាប់គ្នា ៦ទៅ៧នាក់ ។

វណ្ណៈ	ចឹងងាប់មួយឡានប្រហែល៧នាក់?

រិទ្ធៈ	ចាស ។

វណ្ណៈ	មិនមែនគាត់ធ្វើកាចគេគុំសម្លាប់អីទេ?

រិទ្ធៈ	រឿងហ្នឹងធម្មតាដឹកនាំជំនាន់ហ្នឹង ប្រើអំណាចចឹងហើយ ។

វណ្ណៈ	ទោះបីមនុស្សស្លូតក៏ត្រូវតែកាចដែរ?

រិទ្ធៈ	ចាស ។

វណ្ណៈ	គេអប់រំឲ្យផ្តាច់ការ?

រិទ្ធៈ	ចាស!និយាយខ្ញុំដូចគេថាទឹកដោះម្តាយថ្លៃ រស់នៅគេស្លាប់ភាគច្រើន មកនៅដាច់ដោចមក តាមអត្តភាពគេផ្សេងតើ នៅក្នុងអត្តភាពខ្ញុំអត់មានអីទីពឹងស្លាប់ខ្លះចឹងទៅ ។

វណ្ណៈ	ពេលនៅសៀមរាបគេឲ្យមីងធ្វើអី?

រិទ្ធៈ	ខ្ញុំនៅកន្លែងសាំង ដូចថាកន្លែងសាំងហ្នឹងគាត់រៀបចំមានបីនាក់ចឹង មានពូពីរនាក់ខ្ញុំម្នាក់ ។

វណ្ណៈ	ចឹងកាន់ខាងសាំង?

រិទ្ធៈ	ចាស!កាន់សាំង ។

វណ្ណៈ	ចឹងកាន់សាំងរហូតដល់ចប់ឆ្នាំ៧៩ហ្នឹងតែម្តង?

រិទ្ធៈ	ចាស ។

វណ្ណៈ	សាំងហ្នឹងចាក់សម្រាប់ឲ្យខាងណាទៅ?

រិទ្ធៈ	ខ្ញុំអត់ដឹង ។

វណ្ណៈ	មានឡានច្រើនទេ?

រិទ្ធៈ	ចាស!មានឡានមានអីចឹង ។

វណ្ណៈ	ឡានទ័ពឬឡានអី?

រិទ្ធៈ	ឡានដូចជាអត់មានកងទ័ពអីទេ តែពេល៧៩ហ្នឹង ពេលយួនចូលមកដល់សៀមរាបហ្នឹងខ្ញុំរត់ ចេញមក មកខ្ញុំនៅអត់មានអាហារអីចាក់ទេ មានតែអ្នកមកនិយាយទៅអ្នកបើកឡានវាមិន ឃើញស្បៀកពាក់អាហារផង ខ្ញុំមិនអាចដឹង កាលហ្នឹងក្តាប់មិនបានទេខ្ញុំ ខ្ញុំកាន់សាំងគ្រាន់យក ចំនួនគេសាំងពីភ្នំពេញទៅ កន្លែងខ្ញុំហ្នឹងមានអ្នកបើកឡានពីរនាក់ ។

វណ្ណៈ	បាទ ។

រិទ្ធៈ បើកឡានមកចាក់ស៊ីទែនក្នុងដី ស៊ីទែនលើគោកចឹង ចាក់ទៅដល់ពេលចាក់គាត់ឲ្យសំបុត្រមួយ មកឲ្យចាក់ឲ្យឡាននេះប៉ុន្មានលីតៗ យើងចាក់ចឹងទៅ ។

វណ្ណៈ ចឹងចាក់ឲ្យមេៗគណៈតំបន់គណៈភូមិភាគអីទេ?

រិទ្ធៈ ចាស ។

វណ្ណៈ ចឹងសម្រាប់ចាក់ឲ្យមេៗ ?

រិទ្ធៈ ចាស!ឲ្យមេៗហ្នឹង ។

វណ្ណៈ ចឹងនៅកន្លែងសាំងហ្នឹងមីងមានគ្នាប៉ុន្មាននាក់កាលហ្នឹង?

រិទ្ធៈ មានច្រើនដែលធំតែខ្ញុំក្រៅពីនោះក្មេងៗអាយុ១៥ទៅ១៦-១៧អី កាលហ្នឹងខ្ញុំអាយុ១៩-២០ហើយកាលហ្នឹងខ្ទង់២០ទៅ២១អីហ្នឹង ។

វណ្ណៈ មីងការហើយនៅពេលហ្នឹង?

រិទ្ធៈ នៅ ។

វណ្ណៈ ចឹងពេលនៅហ្នឹងគេមានឲ្យតួនាទីមីងជាប្រធានអីខ្លះដែរ?

រិទ្ធៈ ខ្ញុំនៅកន្លែងសាំងខ្ញុំជាសមាជិកគេ ពួៗពីរនាក់ហ្នឹងមានប្រធាននិងអនុប្រធានខ្ញុំសមាជិកបីនាក់ហ្នឹងខ្ញុំជាសមាជិកគេ ។

វណ្ណៈ ប្រធានអីកន្លែងហ្នឹង?

រិទ្ធៈ អត់ទេ ខាងគ្រប់គ្រងសាំង ទទួលសាំងតែម្តងអត់មានស៊ីជង គ្រាន់មើលខុសត្រូវសាំងហ្នឹង ។

វណ្ណៈ ចឹងគ្នានៅហ្នឹងមានគ្នាប្រហែលពី២០ទៅ៣០នាក់ទេ កន្លែងសាំងហ្នឹង?

រិទ្ធៈ កន្លែងសាំងអត់ដល់ទេ មានខ្ទង់៨ទៅ៩នាក់ ហើយក្មេងៗស្រីៗកន្លែងខ្ញុំហ្នឹងស្រីៗ ពួៗសាំងមានបីកន្លែងនោះ នៅភ្នំក្រោមមួយកន្លែង ផ្លូវទៅអង្គរស្ពាននោះមួយកន្លែង កន្លែងព្រះអង្គរ ចេកព្រះអង្គរចមគេហ្នឹង ។

វណ្ណៈ ចឹងសាំងហ្នឹងសម្រាប់ចាក់ឲ្យកម្មាភិបាលទេ?

រិទ្ធៈ ចាស!កម្មាភិបាល មានចាក់អីច្រើនក្នុងមួយខែគេដឹកមកពីរស៊ីទែនអីចឹង ។

វណ្ណៈ ចឹងនៅកន្លែងហ្នឹងមីងមានដឹងថា ប្រជាជនរស់នៅជិតៗខេត្តហ្នឹងដែលឬអត់មាន មានតែកម្មាភិបាលទេ?

រិទ្ធៈ អត់មានប្រជាជនទេ មានកន្លែងកាត់ដេរ និយាយទៅដូចពួកមន្ទីរចឹង អត់មានប្រជាជនទេ ។

វណ្ណៈ ចឹងមានគុកអីទេកាលហ្នឹង?

រិទ្ធៈ អត់មានទេ ខ្ញុំអត់ដឹងទេ ។

វណ្ណៈ ចឹងកន្លែងមីងនៅអត់មានគេចាប់ខ្លួនអីទេ?

រិទ្ធៈ អត់មានទេ កន្លែងខ្ញុំអត់មានគេចាប់ទេ ។

វណ្ណៈៈ ចឹងមីងមានដឹងថា អង្គរវត្តមានភ្ញៀវមកលេងទេពេលហ្នឹង?

រិទ្ធៈ កាលហ្នឹងដូចជាអត់មាន ខ្ញុំទៅដឹក ខ្ញុំគេឲ្យដាំខ្ទឹមដាំជីអី ខ្ញុំទៅដឹកអាចម៍ប្រជៀវមកពីអង្គរវត្ត មក តែមានទាហានមានកងការពារគេនៅចាំអង្គរហ្នឹងតែម្តង ទាហានហ្នឹងគេនៅថែសម្អាតហ្នឹង តែឲ្យមានភ្ញៀវអីអត់មានទេ ។

វណ្ណៈៈ មីងកាលហ្នឹងមានបានចូលមើលក្នុងអង្គរទេ?

រិទ្ធៈ ចូលតើ ។

វណ្ណៈៈ មានឃើញនៅសល់ព្រះអង្គរច្រើនទេ?

រិទ្ធៈ មានសល់ដែរ និយាយទៅនៅសល់ប្រហែលយើងរាល់ថ្ងៃនេះ ឥឡូវក៏ខ្ញុំទៅមើលឥឡូវវា ស្អាតមិនដូចជំនាន់នោះ ជំនាន់មុនចូលទៅធំក្លិនអាចម៍ប្រជៀវអី ។

វណ្ណៈៈ ចឹងដល់ឆ្នាំ១៩៧៩ហ្នឹង មីងអត់មានចង់រត់មករកផ្ទះសំបែងវិញទេ ដឹងថាវៀតណាមចូល នេះ?

រិទ្ធៈ អារម្មណ៍មានចង់ទៅផ្ទះ តែគេថាចេះ បើយើងចូលទៅយួនសម្លាប់អីចឹង ខ្ញុំអត់ហ៊ានទៅទេ នឹកឃើញថាម៉ែរស់អីស្លាប់ យើងអត់ដឹង ហើយមិនដឹងជាយ៉ាងម៉េច មានអារម្មណ៍មួយ យើងមិនចេញស្អីទេ ដឹងថាជំនាន់ប៉ុល ពត ហ្នឹងមានគេសម្លាប់នៅណាចឹងណាស់ មានអារម្មណ៍គិតចឹងដែរ ចង់ទៅឃើញចង់ដឹងថា ម៉ែឪនៅឬអត់ បងប្អូននៅប៉ុន្មានអីប៉ុន្មាន តែពាក្យ ឃោសនាបើទៅយួនសម្លាប់ចោល ទៅកាត់ក្បាលធ្វើថ្នាំអីចឹងណា ។

វណ្ណៈៈ បាទ ។

រិទ្ធៈ ដល់ចឹងមានអារម្មណ៍មួយខ្លាចលែងហ៊ាន មិនហ៊ានទេ ទាល់ផ្តាច់ខ្លួនឥឡូវបានហ៊ានទៅស្រុក ដល់យើងត្រូវគ្នាចឹងណា ។

វណ្ណៈៈ បាទ ។

រិទ្ធៈ បានខ្ញុំទៅដល់ស្រុក ។

វណ្ណៈៈ ចឹងបានទៅដល់ជួបបងប្អូន?

រិទ្ធៈ ជួបបងប្អូន ដឹងបាត់បងបាត់អី បងជីដូនមួយខ្ញុំមួយពូជគេសម្លាប់ឡើងបួននាក់ ។

វណ្ណៈៈ ចឹងមីងមានអារម្មណ៍យ៉ាងម៉េចដែលយើងគិតថា យើងតស៊ូដើម្បីរំដោះជាតិ តែពេលខ្មែរ ក្រហមរំដោះប្រទេសបានហើយ បែរជាមិនឲ្យមានសិទ្ធសេរីភាពអីចឹង មីងមានតូចចិត្តក្នុងការ តស៊ូដែលយើងហត់ ដើម្បីឲ្យប្រទេសជាតិមានសំណាងមានសិទ្ធិសេរីភាព បែរជាកំសត់ជាង របបមុនទៅទៀត មីងមានអារម្មណ៍យ៉ាងម៉េចដែរ?

រិទ្ធៈ អារម្មណ៍មានដល់ពេលទៅបាត់បងប្អូនចឹង នឹកឃើញថា ខ្លួនឯងខំតស៊ូស៊ើរស្លាប់ស៊ើររស់ចឹង ហើយបាត់បង់ចឹង មានអារម្មណ៍មួយគិតថា វិន័យសុទ្ធ១២ប្រការ សូម្បីម្ជុលមួយផ្លែមិនឲ្យប៉ះពាល់ដល់ប្រជាជនទេ ដល់ចឹងបាត់បងប្អូនមានអារម្មណ៍គិតថា ប្រៀបខ្លួនឯងមិនបានដឹងពុទ្ធទទួលនយោបាយតែមួយចឹង ដឹងថាខ្លួនឯងអត់មានប្រជាធិបតេយ្យ ទទួលមាគ៌ាតែមួយ នយោបាយតែមួយ ដល់ចឹងយើងមិនបានដឹងថាហេតុផលយ៉ាងម៉េចៗ ខ្ញុំគិតថាសម័យ ប៉ុលពត វាផ្តាច់ការមែន ទោះបីខ្លួនបានចូលប្រឡូកក្នុងការងារហ្នឹងមែន តែវាមានការសោកស្តាយ សោកស្តាយត្រង់ថា បើមកដល់មិនមានការកាប់សម្លាប់បងប្អូនទេវាមិនសូវអីទេ ដល់បាត់បង់បងប្អូន គេយកទៅសម្លាប់ចោល មានបញ្ហាបន្តិចបន្តួចយកទៅវាយចោលអីចឹង មានអារម្មណ៍ត្រង់ថា ពេលនេះខ្ញុំគិតថា បើខ្ញុំឈឺចាប់ឈាមសងដោយឈាមសង្គ្រាមវាមិនចប់ណាស់ ដល់ហើយខ្ញុំគិតថាមិនដឹងជាធ្វើយ៉ាងម៉េច ទាមទារថាឲ្យសងសាច់សងញាតិក៏មិនដឹងជាទៅយកពីណា ។

វណ្ណៈ បាទ ។

រិទ្ធៈ ចឹងបានថា ចូលមកដល់របបនេះខ្ញុំគិតថា រាល់ថ្ងៃគិតថា បានរំដោះពួកខ្ញុំមកបានចូលជាមួយគ្នាខ្ញុំបានសប្បាយ ព្រោះអីមានសេរីភាពក្នុងការរស់នៅ សូម្បីកូនចៅខ្ញុំបីខ្ញុំពរខ្ញុំរត់ ដែលខ្ញុំមានប្តីហើយនៅរត់ទៀត នៅតែរត់គ្រាប់ផ្លោងពីមុខពីក្រោយ ជួនកាលត្រូវគ្រាប់ផ្លោងស្លាប់ប្រឹងពីមុខ ជួនណាដើរទៅជាន់មីនទីងទៅ គេចពីមីនហ្នឹងទៅទៀតទៅ ខ្លះធ្លាក់កូនចោលបាត់កូនទៅ ម្តាយស្រែកទ្រហោយំទៅធ្លាក់ជ្រោះអីចឹង ។

វណ្ណៈ បាទ ។

រិទ្ធៈ បើគិតទៅជំនាន់ហ្នឹង វាឈឺចាប់ខ្លាំងណាស់ហើយ មានការឈឺចាប់ខ្លាំងណាស់ ព្រោះអីទំរាំបានប៉ុននេះ ខ្ញុំគិតថាសម័យសង្គមនេះអត់មាននេះទេ ព្រោះខ្ញុំគិតថាខ្ញុំខ្មែរក្រហម ខ្ញុំគិតចឹងខ្មែរក្រហមខ្ញុំគិតទៅជាជនគេមិនទុកចិត្តណាស់ ខ្ញុំគិតខ្លួនខ្ញុំចឹង ពេលនេះអ្នកណាធ្វើអី តួនាទីអីគេបានធ្វើតួនាទីហ្នឹងវិញ ខ្ញុំអត់មានគិតអីទៀតទេ ។

វណ្ណៈ បាទ!មកដល់ឥឡូវនេះយើងលែងមានការបែកបែងខ្មែរក្រហមខ្មែរសអីទៀតហើយ?

រិទ្ធៈ ចាស ។

វណ្ណៈ ឥឡូវមានខ្មែរតែមួយ?

រិទ្ធៈ ចាស!ខ្មែរតែមួយ ។

វណ្ណៈ ឲ្យតែខ្មែរស្រឡាញ់គ្នាប្រទេសជាតិយើង មានការជឿនលឿនទៅមុខហើយ?

រិទ្ធៈ ចាស ។

វណ្ណៈ៖ លែងមានបញ្ហាអីហើយ?

រិទ្ធៈ ចាស ។

វណ្ណៈ៖ ចឹងខ្ញុំចង់សួរបន្តនៅពេលមីងរត់នៅឆ្នាំ១៩៧៩នោះ កាលហ្នឹងមីងរត់ទៅតាមអង្គភាពឬមួយមីងរត់ចេះតែរត់មិនបានដឹងទិសតំបន់ឬមួយយ៉ាងម៉េច?

រិទ្ធៈ រត់តាមអង្គភាព ។

វណ្ណៈ៖ ចឹងអង្គភាពគេនាំទៅ?

រិទ្ធៈ ចាស!អង្គភាពនាំទៅ ។

វណ្ណៈ៖ មីងដើរកាត់ព្រៃឬមួយមីងមានឡានជិះដល់ទល់ដែន?

រិទ្ធៈ ដើរ ។

វណ្ណៈ៖ ចឹងចេញពីសៀមរាបទៅដើររហូត?

រិទ្ធៈ ចាស!ចេញពីសៀមរាប គេហៅស្ទឹងទៅខាងលិចវិញ គេហៅភូមិអំពិលភូមិរំដួលអីគេនោះ ទៅដល់ហ្នឹងជួបថៃក្រហមអីហ្នឹង គេចេះជួយរំលែកគេមានទឹកឲ្យយើងផឹកចឹងណាស់ តែពេលរត់ហ្នឹងខ្ញុំវេទនាណាស់ ព្រោះអត់មានបាយហូបតែម្តង រត់ទៅទំរាំដល់ភូមិមួយទៅភូមិមួយចឹងយើងដើរ យើងពិបាកខ្លាំងដែរ យើងរត់ចេញពីសៀមរាបទៅពិបាក ។

វណ្ណៈ៖ ចឹងមានមនុស្សស្លាប់តាមផ្លូវទេ?

រិទ្ធៈ មានស្លាប់រណ្តូករណែល ខ្លះដេកលើអង្រឹងចឹងទៅលែងរួចស្លាប់ យើងមិនដឹងថាតែមនុស្សដេកលក់ តែគ្នាស្លាប់ទេ ហើយចោលកូនងំាតាមផ្លូវគ្មានពីណាជួយយកពីណាទេ ដូចថាម្នាក់ៗយកតែអាត្មាភាពខ្លួនឯងតែម្តង ឃើញយំចោលចឹងទៅ ឃើញដេកដីចោលដី ជួនណាឃើញធ្វើរានក្រងប៉ុនៗនេះដាក់ចោលទៅរំកូនចោលហ្នឹងទៅ វាអត់មានបាយស៊ីចឹងគាត់ហេវ ចឹងប្រឹងយោងតែខ្លួនម្នាក់ៗធ្វើម៉េចឲ្យបានរស់ ។

វណ្ណៈ៖ ចឹងមនោសញ្ចេតនាកូនប្តីដាច់ស្រាច់អស់?

រិទ្ធៈ ចាស!ជិនាន់ហ្នឹងខ្ញុំមិនទាន់មានប្តីដែរ ឆ្នាំ៧៩ខ្ញុំមិនទាន់យកប្តីទេ រត់ទៅហ្នឹងមានតែអង្គភាពដូចថាកន្លែងនារីពួកខ្ញុំហ្នឹង គេឲ្យខ្ញុំទទួលនារីមាន៦៧នាក់ មានមិនមែនតែនារីទាំងអស់ទេ មានកូនក្មេងខ្លះៗមានចំនួន៦៧នាក់ ហើយកាលហ្នឹងគេបើកនាឡិកាវ៉ាដូឲ្យមួយគ្រឿងលក់ឲ្យថៃបាន៧០០បាត កាលនោះ យកលុយនិងឯងទិញអង្ករបបរឲ្យពួកក្មេងៗហ្នឹងហូប ។

វណ្ណៈ៖ ក្មេងៗប៉ុណ្ណា?

រិទ្ធៈ ក្មេងជួនណាធំចឹងជួនណាឈឺចឹងប៉ុនចៅខ្ញុំអីហ្នឹង យើងចេះតែយកតាមទៅឃើញវាទៅតាមចេះតែយកទៅ ជួនកាលមនុស្សក្រមុំអាយុ១៧-១៨-១៥ខ្លះ១២-១៣អីចឹងទៅណាស់

គេឲ្យខ្ញុំគ្រប់គ្រងក្មេងៗហ្នឹងឯង ខ្ញុំលក់វ៉ាដូហ្នឹងបាន៧០០បាតហ្នឹងទិញអង្ករមកបបរ ដល់បានទៅដល់ខ្មែរនេះ បានមានឡានខាងកាកបាទក្រហមខាងបារាំងគេហ្នឹងគេដឹកអង្ករយកមកចែក តែក្នុងនាមហូបបបរដដែលហ្នឹង ហូបបបរឡាយដើមចេកលាយដើមល្ហុងលាយដំឡូងថៃ មិនមានអង្ករហូបគ្រប់គ្រាន់ទេ គិតប្អូននាក់ឲ្យមួយកំប៉ុង កាលហ្នឹងអង្ករមនុស្សធម៌គេដឹកមកអត់ទាន់ចឹង ។

វណ្ណៈ: ចឹងកាលហ្នឹងបានជួបអង្គការកាកបាទក្រហមមានរាំងអីហ្នឹង យើងគិតថាបានរស់ហើយពេលហ្នឹង?

រិទ្ធៈ: ចាស!គិតថាបានរស់ហើយ តែមិនទាន់បានគ្រប់គ្រាន់ទេ នៅហូបបបរ មិនទាន់បានហូបបាយទេ យើងទៅដល់ជំរុំហ្នឹង តែយើងដឹងថាយើងរស់ហើយលែងអីហើយ តែយើងដឹកដំឡូងថៃ ថៃ ដេរផងយើងស្តាប់មិនបានដឹកទៅ ដឹកយកមកលាយបបរ បើយើងដាំបាយហូបមិនគ្រប់ទេ បបរលាយស្លឹកឈើពួកខ្ញុំពុលស្លឹកឈើហ្នឹង យើងប្រទ្បាំគេថាបន្លែហ្នឹងអត់អីចឹង ស្លឹកដូចគ្នាយកមកបបរពុល ។

វណ្ណៈ: ចឹងមានពុលទៀត?

រិទ្ធៈ: ចាស!មានពុល តែគ្រាន់ថាពួកខ្ញុំស្លាប់អស់ពីរនាក់ វាគ្រុន ។

វណ្ណៈ: កាលហ្នឹងយើងអត់អាហារហើយចាញ់ទៀត?

រិទ្ធៈ: ចាស!ចាញ់គ្រុនទៅចឹងថ្នាំពេទ្យក៏យើងមិនសូវសម្បូរដែរ ពេលគ្រុនទៅយើងដល់នេះគេហៅចម្ការចេកហ្នឹង ដល់គ្រង់ហ្នឹងយើងធូរវិញហើយ ដល់ហ្នឹងយើងឈឺធ្ងន់គេដឹកយកទៅមើលនៅថៃ អង្គការហ្នឹងគេយកទៅមើលទៅ ជួនណាក្តៅៗប្រកាច់ធ្លាក់ពីលើគ្រែទៅងាប់ ។

វណ្ណៈ: ចឹងកាលរត់ហ្នឹងមានជំងឺគ្រុនចាញ់ដោយសារមានព្រៃឈើច្រើន?

រិទ្ធៈ: ព្រៃឈើធំៗណាស់សុទ្ធតែព្រៃ រុកក្នុងព្រៃសុទ្ធព្រៃ ។

វណ្ណៈ: ចឹងអត់មានខ្លាចសត្វធាតុខ្លាដំរី?

រិទ្ធៈ: អត់មានខ្លាចទេ មនុស្សរាប់ម៉ឺន ។

វណ្ណៈ: ចឹងកាលហ្នឹងមានមនុស្សច្រើន?

រិទ្ធៈ: មនុស្សរាប់ម៉ឺននោះខាប់ទាំងអស់ ។

វណ្ណៈ: ចឹងមានស្លាប់ច្រើន?

រិទ្ធៈ: ស្លាប់ក៏ច្រើនដែរ ស្លាប់និងឈឺផងយើងអត់បាយផងនិយាយទៅ ។

វណ្ណៈ: ចឹងខ្ញុំចង់ឲ្យមីងរៀបរាប់ពេលមីងទៅដល់ខ្មែរហើយ មីងបន្តទៅដល់ណាទៀតបានមកដល់ភ្នំដងរែកហ្នឹង?

រិទ្ធៈ ខ្ញុំទៅកន្លែងច្រើនណាស់ រត់ទំរាំដល់ខ្សែមវាមានច្រើនកន្លែង គេហៅអូរសដុង អូរពេជ្រចិន្តាអីចឹង សុទ្ធតែកន្លែងស្លាប់ច្រើនហើយបានទៅដល់ខ្សែមហ្នឹង គេឲ្យយើងទៅជាប់ជិតថៃ យើងនៅឆ្ងាយក្នុងព្រៃដែលហ្នឹង ។

វណ្ណៈ បាទ ។

រិទ្ធៈ ដល់ពេលក្រោយមកទៀតបានទៅនៅគេហៅចម្ការចេក ចម្ការដូងទៅនៅហ្នឹងលែងអីវិញហើយ នៅហ្នឹងធូរខាងអង្គការមនុស្សធម៌គាត់ចេញចូលបានចឹង មានថ្នាំពេទ្យមានអីគេមានប្រដាប់គេមកពិនិត្យជួសឈាមមើលជំងឺស្អីគេឲ្យថ្នាំទៅ បើធ្ងន់ធ្ងរគេដឹកយកទៅក្នុង ។

វណ្ណៈ ចឹងមីងមានបានទៅដល់ម៉ាឡៃអីទេ?

រិទ្ធៈ ម៉ាឡៃដល់ស្គាល់ទាំងអស់ តែមិនដឹងជារៀបរាប់ខាងណាមុនខាងណាក្រោយ ម៉ាឡៃគេហៅអូរល្ហុងអីហ្នឹង ។

វណ្ណៈ ចឹងមីងនៅខាងព្រំដែនដូរម៉ាឡៃនោះ ហេតុអីបានជាមីងមកដល់ខាងនេះទៀត?

រិទ្ធៈ ខ្ញុំមកខាងនេះវិញ ចេះខាងអង្គភាពខ្ញុំហ្នឹងគេមកនៅគេហៅអណ្ដែងមុតហ្នឹង គេដកពួកខ្ញុំមកនៅហ្នឹង គេដកពួកខ្ញុំមកនៅហ្នឹង ដឹកជញ្ជូនគ្រាប់យកទៅឲ្យអ្នកមុខ ។

វណ្ណៈ អណ្ដែងមុតហ្នឹងនៅណាវិញ?

រិទ្ធៈ អណ្ដែងមុតហ្នឹងនៅត្រង់ណាទេ ដូចខាងបន្ទាយមានជ័យជឹងឧត្ដរមានជ័យ ។

វណ្ណៈ ចឹងគេយកមីងពីខាងម៉ាឡៃមកវិញ?

រិទ្ធៈ ចាស ។

វណ្ណៈ ពីណាទៅយក?

រិទ្ធៈ កាលហ្នឹងអង្គភាពហ្នឹង ដូចថាកងពលខ្ញុំស្លាប់អស់ហើយចឹង មានវរសេនាធំគេគ្រប់គ្រងចឹងគេដកពីហ្នឹងមកឲ្យពួកខ្ញុំមកដឹកជញ្ជូន ។

វណ្ណៈ ពេលរត់មកដល់ម៉ាឡៃហ្នឹងមានបានជួបលោកតាអៀង សារី តាខៀវ សំផន អីទេ?

រិទ្ធៈ ខ្ញុំជួបតើ ។

វណ្ណៈ ចឹងបានជួប?

រិទ្ធៈ ចាស!ខៀវ សំផន ខ្ញុំជួបទាំងប្រពន្ធគាត់ តែពេលជួបយើងមិនបាននៅជិតទេ ឋានៈគាត់ធំចឹងយើងគ្រាន់បានត្រឹមឃើញមុខគ្នាជួបឃើញចឹងទៅ កន្លែងរស់នៅរបស់គាត់យើងមិនដែលដឹងទេ ខ្ញុំជួប អៀង សារី ខៀវ សំផន ហើយ បងរិន ប្រពន្ធខៀវ សំផន អីខ្ញុំបានជួបតើកាលហ្នឹង ។

វណ្ណៈ ចឹងមីងនៅដល់ម៉ាឡៃ ខ្សែម ហ្នឹងដលឆ្នាំណាបានមីងមកនៅនេះ?

រិទ្ធៈ ឆ្នាំ៨០ ឆ្នាំ៨០គេបញ្ជូនពួកខ្ញុំទៅនោះទៀត គេហៅ១០០១ ទន្លេល្អៅទៀតនោះនិយាយទៅម៉ាដួរព្រំដែនសៀមដល់លាវនោះ គេឲ្យទៅដឹកជញ្ជូនខ្ញុំឆ្នាំ៨០មិនទាន់យកប្ដីទេ ខ្ញុំយកឆ្នាំ៨២ហើយហ្នឹង ។

វណ្ណៈ ចឹងទៅដល់១០០១ហ្នឹងពីណាជាអ្នកគ្រប់គ្រង?

រិទ្ធៈ កន្លែងហ្នឹង សុន សេន ។

វណ្ណៈ ចឹងកាលមីងនៅ១០០១គេឲ្យមីងធ្វើអី?

រិទ្ធៈ គេឲ្យខ្ញុំដឹកជញ្ជូន ។

វណ្ណៈ ចឹងមានជញ្ជូនអីខ្លះកាលហ្នឹង?

រិទ្ធៈ ជញ្ជូនអង្ករមានគ្រាប់ ចំរ៉ូង ។

វណ្ណៈ ចឹងចំរ៉ូងមានធ្វើតាំងពីឆ្នាំហ្នឹងមកទៀត?

រិទ្ធៈ ចាស!ចំរ៉ូងបិទធ្វើខ្លួនឯងជញ្ជូនខ្លួនឯងចឹង ។

វណ្ណៈ តាំងពីឆ្នាំ៨០មក?

រិទ្ធៈ ចាស ។

វណ្ណៈ ចឹងចំរ៉ូងមិនមែនទើបកើតក្រោយនេះទេ?

រិទ្ធៈ មិនមែនទេ ចំរ៉ូងកើតតាំងពីហ្នឹងមក ។

វណ្ណៈ ហេតុអីបានជាយើងមានគ្រាប់ហើយ យើងចាំបាច់ធ្វើចំរ៉ូងទៀត?

រិទ្ធៈ ចំរ៉ូងខ្ញុំអត់ដឹងដែរ ដឹងថាយ៉ាងម៉េច កិច្ចការរបស់កងពលកាលហ្នឹងគេឲ្យធ្វើចំរ៉ូង គេកំណត់ទៀតក្នុងម្នាក់ក្នុងមួយថ្ងៃឲ្យបាន៣០០ចំរូង ដូចអ្នកមានប្ដីហើយចឹងគេឲ្យសម្រាកដែរ បើអ្នកមានផ្ទៃពោះនៅបីខែទៀតគ្រប់ខែចឹង គេឈប់ឲ្យយើងធ្វើហើយ ព្រោះអ្នកកាប់ចំរ៉ូងប្ដីយើងទៅវាយខាងមុខ យើងនៅស្រីៗធ្វើទៅកាប់ឫស្សីឡើងឫស្សីខ្លួនឯង អត់មានប្ដីមកជួយយើងទេ ។

វណ្ណៈ ចឹងយើងកាប់រំលំឫស្សីខ្លួនឯង?

រិទ្ធៈ ចាស!ឫស្សីទំរាំបានមួយដើមៗយកមកអារកង់ៗអង្គុយបិទខ្លួនឯង ។

វណ្ណៈ ចឹងឫស្សីហ្នឹងអារប្រហែលជាប៉ុន្មានគីតទៅ?

រិទ្ធៈ ប្រហែលជាបីគីតអី ហើយយើងបិទចុង កាំបិតប្រទូសគេបើកឲ្យ គេបិទមួយកាំបិតចេះទៅទុកទៅមួយថ្ងៃឲ្យបាន៣០០ ។

វណ្ណៈ ចឹងបិទស្រួចចុងស្រួចដើម?

រិទ្ធៈ ចាស!បិទស្រួចសងខាងនិយាយទៅដូចថាបីជ្រុង ។

វណ្ណៈ	ចឹងបិទហើយយកទៅដាក់សមរភូមិមុខដើម្បីដាក់ទប់ស្កាត់ទាហានខាងរដ្ឋាភិបាល?
រិទ្ធៈ	ចាស ។
វណ្ណៈ	ចឹងហ្នឹងខោអាវអាវុធសម្ភារអីបានមកពីប្រទេសណាជួយដែរ?
រិទ្ធៈ	ប្រទេសចិន ។
វណ្ណៈ	ចឹងនៅ១០០១អីតាម៉ុក គាត់មានដើរទៅដល់ហ្នឹងទេ?
រិទ្ធៈ	តាម៉ុក ទេតាម៉ុក គាត់អត់មកទេ មានតែតាសុន សេន ។
វណ្ណៈ	ចឹងអនុតាសុន សេន មីងមានស្គាល់ទេ?
រិទ្ធៈ	អត់ទេ ។
វណ្ណៈ	ចឹងកាលហ្នឹងមីងមិនទាន់មានគ្រួសារគេឲ្យដញ្ជូនគ្រាប់?
រិទ្ធៈ	ចាស!ដញ្ជូនគ្រាប់ ។
វណ្ណៈ	យើងដញ្ជូនគ្រាប់ចឹងមានគ្រោះថ្នាក់ដែលទេ?
រិទ្ធៈ	មានតើ ជួនកាលយើងទៅចឹងទៅ យើងអត់ដឹងគេកន្ទ្រាក់មីននោះ ជួនកាលគ្រោះថ្នាក់អស់ ១០ទៅ២០នាក់ចឹង ដឹកដញ្ជូនអត់មានប្រុសទេ គឺទៅសុទ្ធតែស្រីៗតែម្ដង ។
វណ្ណៈ	ចឹងកាលមានសង្គ្រាមហ្នឹង មីងមានដឹងថាខាងវៀតណាមមានស្លាប់ច្រើនទេ យួនងាប់ច្រើន?
រិទ្ធៈ	កាលហ្នឹងងាប់ច្រើនដែរ គ្រាន់តំបន់ហ្នឹងងាប់ច្រើនណាស់ តាមសាលារៀននេះអី ឃើញខាងវៀតណាមមកគាស់ខ្មោចអីចឹង គាត់មកគាស់កន្លែងសាលារៀនហ្នឹងប៉ុន្មាននាក់ដែរ គាត់មកស្នាក់នៅហ្នឹងគេជូន និយាយរួមទៅពូៗគាត់ដឹង ជូនទៅយកឆ្អឹង ។
វណ្ណៈ	គាស់សម័យឥឡូវហ្នឹង?
រិទ្ធៈ	ចាស!សម័យឥឡូវហ្នឹង ឆ្នាំទៅឆ្នាំទៅមួយអីហ្នឹង ។
វណ្ណៈ	ចឹងពេលមីងចេញពី១០០១មីងមានចេញទៅខាងណាទៀតទេ?
រិទ្ធៈ	ចេញពី១០០១មកខ្ញុំនៅដឹកដញ្ជូនបានប៉ុន្មានខ្ញុំមានប្ដីចឹង ខ្ញុំមានប្ដីខ្ញុំឈប់ហើយ ។
វណ្ណៈ	ចឹងមីងការឆ្នាំ១៩៨២?
រិទ្ធៈ	ចាស ។
វណ្ណៈ	ការចាប់គូរដែលឬការត្រឹមត្រូវ?
រិទ្ធៈ	អត់មានចាប់គូរទេ អត់ការទេគ្រាន់តែមេរៀបចំឲ្យចឹង គ្រាន់ថាយើងពេញចិត្តដែរ មិនមែនបង្ខំដូចជំនាន់កាលមុន យើងអត់ពេញចិត្តក៏ឲ្យយើងយកចឹង តែនេះយើងជ្រើសរើសខ្លួនឯងបាន ។
វណ្ណៈ	ចឹងធូរជាងជំនាន់បីឆ្នាំ?

រិទ្ធៈ ចាស។ ! ផ្លូវដាំងមិនដូចជីនាន់បីឆ្នាំ ។

វណ្ណៈៈ ចឹងមឹងនៅ១០០១រហូតឬមួយយ៉ាងម៉េច?

រិទ្ធៈ នៅ១០០១រហូត នៅ១០០១ហើយបានគេដឹកពី១០០១មកគេដឹកទៅគេហៅស្អីទេ នៅជិតនេះមកតាមជងភ្នំកាត់តាមស្រុកថៃហ្នឹងមកនៅហ្នឹង ដូចថាគេដូរកងពលចឹងមកនៅខាងស្រែព្រៃហ្នឹង បានចុះពីស្រែព្រៃមកជាំស្លានេះភ្នំដីថៃហ្នឹង បានចុះមកនៅនេះតែម្ដង ។

វណ្ណៈៈ ចឹងមឹងចុះមកដល់ទំនប់ដាច់នៅឆ្នាំណា?

រិទ្ធៈ ឆ្នាំ១៩៨៦ ។

វណ្ណៈៈ ឆ្នាំ៨៦បើតាមខ្ញុំគិតនៅមានសង្គ្រាមជាមួយវៀតណាម?

រិទ្ធៈ ចាស! នៅតើ មកនៅបានប៉ុន្មានធ្វើផ្ទះអីហើយ ពួកវៀតណាមមកវាយនេះថាមានស្លាប់នៅសាលារៀននេះ ខ្មែរក្រហមធ្វើសាលារៀនឲ្យក្មេងរៀនចឹង ពួកខ្ញុំជម្លៀសរត់នៅខាងលិចទៀត ផ្ទះអីនៅចោលចឹង ផ្ទះកាលហ្នឹងគេបើកស៊ីប្រូឲ្យ យើងអារឈើខ្លួនយើងកាលហ្នឹងសម្បូរឈើ ដល់រត់ចោលចឹងទៅពួកទាហានរដ្ឋាភិបាលរុះយកស៊ីប្រូប្រមូលដឹកយកទៅខាងចារស្រអែមនោះ ដឹកដំបូលផ្ទះពួកខ្ញុំទៅ ដល់មកវិញនាំគ្នាធ្វើសាជាថ្មីទៀតទៅ ។

វណ្ណៈៈ ចឹងនៅជុំវិញហ្នឹងសុទ្ធតែព្រៃធំៗ?

រិទ្ធៈ សុទ្ធតែព្រៃនេះមានសុទ្ធតែព្រៃ ហើយមកនៅនេះដំបូងអត់មានទឹកហូបទេ ទឹកមាននៅកន្លែងត្រពាំងប្រាសាទ មុខសាលាស្រុកនោះ មានតែកន្លែងហ្នឹងតាំងពីដើមមក របស់បុរាណទេ កន្លែងស្រះមុខសាលាស្រុកមួយចំហៀងខាងនេះនោះ ។

វណ្ណៈៈ ចឹងមានត្រពាំងទឹកនៅហ្នឹង?

រិទ្ធៈ ចាស! ត្រពាំងទឹកនៅហ្នឹង ឡានទៅដឹកទឹកមកចែកគ្នា អត់មានទឹកដឹកទេមកដល់ដំបូង បានឮ០៥តាសារឿន ហ្នឹង គាត់នាំពួកខ្ញុំជីកទំនប់ហ្នឹង ទំនប់នេះមុនដំបូងលើកនិងដៃទេ ដូចថាយើងលើកធ្វើស្រែធំចឹង លើកឲ្យទឹកដក់ ក្រោយមកទៀតគាត់បានយកគ្រឿងចក្រមកធ្វើធំ បានទឹកហ្នឹងប្រើទៅ ។

វណ្ណៈៈ ឥឡូវមានទំនប់ហ្នឹងទៅ?

រិទ្ធៈ មានទំនប់នេះ គាត់ធ្វើផ្ទះគាត់ទៀត តែឥឡូវផ្ទះហ្នឹងរុះអស់ហើយ ទាហានគេរុះថាធ្វើថ្មីឥឡូវអត់ទាន់បានធ្វើផង ។

វណ្ណៈៈ ចឹងមឹងពេលយើងចុះមកនៅហ្នឹងពិតប្រាកដបានឆ្នាំណាដែលតាម៉ុក ចុះមកធ្វើផ្លូវនៅហ្នឹងយើងឈប់រត់អីឆ្នាំណា?

រិទ្ធៈ មិនដឹងជាឆ្នាំប៉ុន្មានទេ ព្រោះអីចេះ គេធ្វើផ្លូវតាំងពីមុនដាច់ខ្លួន មុនត្រូវគ្នាដល់ចុះមកគាត់មានរៀបចំមានទឹកឲ្យយើងប្រើប្រាស់ហើយ ចាប់ផ្ដើមគ្រឿងចក្រធ្វើផ្លូវតែម្ដង គ្រាន់ថាជំនាន់ហ្នឹងធ្វើផ្លូវសគ្រួសក្រហម ។

វណ្ណៈ តាម៉ុកធ្វើកាលហ្នឹង?

រិទ្ធៈ ចាស ។

វណ្ណៈ ចឹងកាលហ្នឹងមានដឹងថា តាប៉ុល ពត តានួន ជា គាត់មកនៅខាងតាម៉ុកហ្នឹងដែរ មីងមានដឹងទេ?

រិទ្ធៈ ខ្ញុំអត់ចាំទេ គ្រាន់ដឹងថា កាលហ្នឹងពួកគាត់នៅខាងក្បាលទន្សោងហ្នឹង វាមិនបានចាំឆ្នាំ កាលជំនាន់ហ្នឹងវាមាន អ្នកគ្រប់គ្រងខ្ញុំគេហៅតា០៥ហ្នឹងមកនៅនេះ ផ្ទះគាត់នៅត្រង់នោះ គាត់នៅហ្នឹងគាត់ប្រធានខាងកងទ័ព ដល់ក្រោយមកទៅផ្ទៃក្នុងមានវាយគ្នា ដល់ស្លាប់តាសុនសេន ហ្នឹងបានខាងតាម៉ុក មកចាប់តា០៥តា០៦ហ្នឹងយកទៅដាក់គុកគេវាយចោលអស់ទៅកាលហ្នឹង ។

វណ្ណៈ ចឹងមីងមានដឹងថា ហេតុអីធំៗដែលធ្លាប់និយាយលេងសើចជាមួយគ្នាធ្លាប់ធ្វើការជាមួយគ្នាហើយមានសម្លាប់គ្នាឯងចោលចឹង?

រិទ្ធៈ កាលហ្នឹងគេនិយាយថាក្បត់ គេចង់ថាតា០៥តា០៦ហ្នឹងក្បត់ត្រូវគ្នាជាមួយខាងរដ្ឋាភិបាលចឹង តាមមើលបែបចឹងមែនដំណើរគាត់ឃើញកងទ័ពស្លាប់ច្រើន គាត់មានទំនាក់ទំនងតាមខ្ញុំស្មាន ដំណើរគាត់ចង់ផ្សះផ្សារដើម្បីឲ្យចប់សង្គ្រាមចឹងទៅបានគេដឹងចឹងឬមួយមិនពិតម៉េចមិនដឹងទេ តាមមើលព្រោះអីចេះ ក្រោយមកគេចាប់តា០៥តា០៦ប្រពន្ធកូនអីយកទៅដាក់គុកចឹងទៅ មានមេមួយចំនួនទៅសារភាព តាកែវ តាជុំ អីហ្នឹងគាត់ស្គាល់ទេ ។

វណ្ណៈ ស្គាល់ ។

រិទ្ធៈ ចាស!បងជុំ បងកែវ អីហ្នឹង ទៅឃុំលនៅផ្ទះជិតៗចឹង តែពួកខ្ញុំមិនបានដឹងទេ អត់មានដឹងថាគេទៅណាមកណាទេ ដល់ទៅចឹងទៅបានប៉ុន្មានថ្ងៃទេ គាត់មកវិញ កាលហ្នឹងគាត់ទៅប្រហែលជាប៉ុន្មានទេ ចាំគាត់មកវិញថ្ងៃទី២០គាត់មកគាត់ហៅពួកមកប្រជុំ គាត់ថាកុំភ័យខ្លាចអី គាត់ទៅដល់ថ្នាក់ខេត្តធំៗគ្មានយួនទេ ការឃោសនាយួនកាត់ក្បាលអីចឹង គាត់ថាអត់មានយួនទេ ជឿគាត់ទៅគាត់និយាយហើយគាត់យំផង ព្រោះអីគាត់ចូលចឹងគេតាម ។

វណ្ណៈ តាកែវអីហ្នឹង?

រិទ្ធៈ ចាស!គេតាមឡានគេតាមទាហានគេតាមបាញ់ចោលតាមផ្លូវ តែគាត់ចេះគេចរួចដល់គាត់មកគាត់យំ ។

វណ្ណៈ   ចឹងកាលហ្នឹងគាត់ចូលទៅក្នុងហើយគាត់ចូលមកវិញខាងតាម៉ុក អត់មានរករឿងទេចឹង?
រិទ្ធៈ   តាម៉ុក គាត់គេចឡើងភ្នំអស់វិញហើយ ។
វណ្ណៈ   ចឹង?
រិទ្ធៈ   ចាស!ខាងរដ្ឋាភិបាលមកដេញអស់ហើយបាន គាត់មក ។
វណ្ណៈ   ចឹងគាត់មកដោយសារគាត់ខាងទាហានរដ្ឋាភិបាលដេញខាងទាហានតាម៉ុក?
រិទ្ធៈ   ចាស ។
វណ្ណៈ   ចឹងដូចថារឿងតាសុន សេន ស្លាប់ហ្នឹងបើនៅខាងអន្លង់វែងថា តាសារឿន តា០៥ហ្នឹងជាបក្សពួកខាងតាប៉ុល ពត?
រិទ្ធៈ   ខ្ញុំអត់ដឹងដែលកាលហ្នឹង និយាយរួមទៅផ្ទៃក្នុងខ្ញុំក្តាប់មិនបាន បើបានធ្វើមេអីទៅខ្ញុំបានទៅរៀនអន្តប្រជុំអី ដល់យើងអត់មានធ្វើអីចឹងក្តាប់មិនបានទេ ។
វណ្ណៈ   ហើយគេនិយាយថា ពេលតា សុន សេន ស្លាប់ហ្នឹងតា០៥តា០៦ជាអ្នកទៅសម្លាប់គេនិយាយចឹង ចឹងបើតាមគិតថាគាត់មែនឬមិនមែនគាត់?
រិទ្ធៈ   តែតាមពាក្យចាមអារាមថាចឹង ពូ០៥-០៦ហ្នឹងទៅសម្លាប់តាសុន សេន ថាចឹង តែមានតើបើចង់ច្បាស់យកពត៌មានខាងចឹង កូនគាត់នៅតើ តា០៥ មានបានទៅសម្លាសគាត់ទេ ។
វណ្ណៈ   មានគ្នាខ្ញុំទៅជួបដែរ កូនគាត់និយាយថា ពេលតាសុន សេន ស្លាប់ហ្នឹងឪគាត់នៅនេះហ្នឹងអត់មានបានទៅផង ។
រិទ្ធៈ   ចឹងកាលហ្នឹងនៅហ្នឹងមែន នៅនេះមែនតែខ្លាចថាគាត់មិនចេញទៅខ្លួនឯង មានបទបញ្ជា តែកាលហ្នឹងគាត់នៅនេះមែន គាត់អត់ទៅធ្វើខ្លួនឯងផ្ទាល់ដៃ រឿងហ្នឹងខ្ញុំក្តាប់មិនបានទេ ខ្ញុំអត់ដឹងរឿងហ្នឹងវាជម្រៅនិយាយរួមទាល់ផ្ទៃក្នុងជ្រៅ ព្រោះអីមេប៉ុណ្ណណឹហើយ ។
វណ្ណៈ   ចឹងកាលហ្នឹងខ្មែរក្រហមចេះតែបែកមុខហើយ?
រិទ្ធៈ   ចាស!បែកគ្នា ។
វណ្ណៈ   ចឹងមីងមានដែលជួបតាម៉ុកផ្ទាល់ទេ?
រិទ្ធៈ   ខ្ញុំបានជួបគាត់ផ្ទាល់ ។
វណ្ណៈ   ចឹងអត្តចរិកគាត់យ៉ាងម៉េចដែរ?
រិទ្ធៈ   គាត់កាច ដូចថាតា០៥-០៦អីហ្នឹងគាត់ដេរហៅអា កាលហ្នឹងគាត់ហៅប្រជាជនប្រជុំ គាត់ថាអាសារឿន អាសាន វាក្បត់ជាតិ គាត់និយាយចឹង វាក្បត់ជាតិ គាត់ថា តាសាន តា០៦ហ្នឹង កាលនៅខេត្តក្រចេះហ្នឹងយកមាសអីណាអត់ប្រគល់ឲ្យរដ្ឋអីចឹង ហើយដួកដីរីអីណាទេ គាត់លើករឿងហ្នឹង ខ្ញុំក្តាប់មិនបានដែរ ព្រោះនៅខាងហ្នឹងខ្ញុំមិនដែលនៅជាមួយគាត់

និយាយទៅខ្ញុំនៅអគ្គភាពផ្សេង ពេលខ្ញុំនៅអគ្គភាពជាមួយតាម០៥ខ្ញុំយកប្ដីខ្ញុំ ប្ដីខ្ញុំគាត់នៅខាងហ្នឹង ខ្ញុំនៅផ្សេងចឹង កាលពីមុនខ្ញុំនៅខាងភូមិភាគកណ្ដាល ។

វណ្ណៈ: បាទ ។

រិទ្ធៈ: បងខ្ញុំ តាពក ហ្នឹងត្រូវជាបងថ្លៃខ្ញុំ ។

វណ្ណៈ: ចឹង?

រិទ្ធៈ: ចាស ។

វណ្ណៈ: ចឹងតាពក ត្រូវជាបងថ្លៃ?

រិទ្ធៈ: ចាស!តែបងថ្លៃឆ្ងាយដែលហើយ ម៉ែក្មេងគាត់និងឪពុកខ្ញុំហ្នឹងគាត់ត្រូវជាបងប្អូនជីដូនមួយ ចឹងប្រពន្ធគាត់និងខ្ញុំត្រូវជាជីទួតមួយហើយ ឆ្ងាយគ្នា ។

វណ្ណៈ: បាទ ។

រិទ្ធៈ: កាលហ្នឹងខ្ញុំនៅកងពលនិរតីហ្នឹង គាត់ដឹងថា ដាច់ដោចចឹង អ៊ឹ ពក ទៅយកខ្ញុំមក គាត់រៀបរាបថា អញបងប្អូន អញត្រូវជាបងថ្លៃអីចឹងណា ខ្ញុំក៏នៅជាមួយគាត់ចឹងទៅ ។

វណ្ណៈ: ចឹងនៅជាមួយតាពក?

រិទ្ធៈ: ចាស ។

វណ្ណៈ: តែក្រោយឆ្នាំ១៩៧៩ តាពក ដូចជាគាត់មិនសូវមានឥទ្ធិពលអី?

រិទ្ធៈ: អត់មាន ។

វណ្ណៈ: គេធិបគាត់ដែរ?

រិទ្ធៈ: ចាស ។

វណ្ណៈ: តែគាត់មានកាន់កងពលដែល៤១៧ហ្នឹង?

រិទ្ធៈ: ចាស!គាត់កាន់៤១៧ហ្នឹង ។

វណ្ណៈ: តែមិនសូវឮឈ្មោះ ប៉ោះសម្លេងដូចតា០៥?

រិទ្ធៈ: ចាស!ម្យ៉ាងគាត់ចាស់ជាងតា០៥ ដល់ចឹងការរៀបចំដឹកនាំគេច្រើនរកអ្នកចុះជាប់សមរភូមិដែរ ដូចតា០៥តា០៦វិយគាត់នៅក្មេងជាង អ៊ឹ ពក ចឹង ដល់ចឹងចុះជាប់សមរភូមិតា០៥តា០៦គាត់ចុះផ្ទាល់ទៅជាមួយទាហាន អ៊ឹ ពក គាត់ចាស់ហើយ ណាមួយគាត់លើសឈាមតាំងពីសម័យហ្នឹងមកម្លេះ គាត់លើសឈាមអ៊ឹ ពក នោះ ។

វណ្ណៈ: ចឹងគាត់លើសឈាមតាំងពីសម័យខ្មែរក្រហម?

រិទ្ធៈ: ចាស!ពេលគាត់ទៅមុខអគ្គភាពគគាត់ទៅចឹង ពេលហ្នឹងគាត់ធ្វើទុកឈាមអី គាត់ធ្វើទុកចឹងធ្វើការវាមិនលឿន ដូចនេះវាបាត់មុខបាត់សម្លេងវាត្រូវតែបាត់ វាអត់មានក្នុងចលនា ។

វណ្ណៈ៖ ចឹងប្ដីមីងនៅក្នុងកងពលណា?

រិទ្ធៈ នៅក្នុងកងពល៨០១ ។

វណ្ណៈ៖ ចឹងមីងនៅក្នុងកងពលហ្នឹងដែលទៅ?

រិទ្ធៈ ចាស!ដល់បានគ្នាខ្ញុំបានមកនៅក្នុងអង្គភាពប្ដីខ្ញុំមកណា ពីមុនខ្ញុំនៅភូមិភាគកណ្ដាលនៅជាមួយ អ៊ំ ពក នៅភូមិភាគកណ្ដាល ។

វណ្ណៈ៖ ចឹងនៅក្នុងកងពល៨០១មកនៅតាំងពីឆ្នាំមីងការហ្នឹង?

រិទ្ធៈ ចាស ។

វណ្ណៈ៖ ចឹងឆ្នាំ១៩៨០នៅជាមួយតាពក?

រិទ្ធៈ ចាស!នៅជាមួយតាពក ។

វណ្ណៈ៖ មានតាពក តាសុន សេន ដែរ?

រិទ្ធៈ ចាស!សុន សេន គ្រាន់ថាគាត់នៅខាងលើគ្រប់គ្រងលើតាពក លើតាសាន ចឹងណា ។

វណ្ណៈ៖ ចឹង?

រិទ្ធៈ ចាស!គាត់ធំជាងគេ សុន សេន គាត់លើតាពក លើតា០៥ បើធំគឺ សុន សេន មួយប៉ែក ខាងទន្លេល្ដៅហ្នឹង ។

វណ្ណៈ៖ ចឹងបើខាងភ្នំដងរែកតាម៉ុក?

រិទ្ធៈ ចាស ។

វណ្ណៈ៖ ចឹងមីងកាលអ៊ុនតាក់ចូលមក មីងមានបោះឆ្នោតទេ?

រិទ្ធៈ កាលអ៊ុនតាក់ចូលមកបានបោះតើ កាលហ្នឹងវិន័យបោះឆ្នោតមិនបានគ្រប់គ្រាន់ដូចយើងឥឡូវ ណាស់ បោះមកជំនាន់ហ្នឹងអត់មានគណៈបក្សណាចូល ។

វណ្ណៈ៖ មីងទៅបោះនៅណា?

រិទ្ធៈ បោះនៅផ្ទះទឹកហ្នឹង ផ្ទះតាសាន ហ្នឹងពីមុន ។

វណ្ណៈ៖ ចឹងមានអ៊ុនតាក់ចូលមកដល់ហ្នឹងដែរ?

រិទ្ធៈ ចាស ។

វណ្ណៈ៖ ចឹងអត់មានខាងខ្មែរក្រហមអុកឡុកអីទេ?

រិទ្ធៈ អត់ទេ បោះឆ្នោតកាលហ្នឹងឆ្នាំ៨៨មួយសារ អូរឆ្នាំ៨៨អត់មានបោះទេ ។

វណ្ណៈ៖ ឆ្នាំ១៩៩៣បានមានអ៊ុនតាក់មក?

រិទ្ធៈ ៩៣ពួកខ្ញុំបានបោះហើយ បោះនៅហ្នឹង ។

វណ្ណៈ៖ បោះលើកទី១ កាលអ៊ុនតាក់ចូលមក?

រិទ្ធៈ ចាស ។

វណ្ណៈ ចឹងកាលហ្នឹងខាងខ្មែរក្រហមផ្ដាច់ខ្លួនយ៉ាងម៉េចបានបោះ ព្រោះកាលហ្នឹងខាងខ្មែរក្រហមមិនព្រមចូលរួមបោះឆ្នោតទេ?

រិទ្ធៈ អត់ទេ កាលហ្នឹងបោះទាំងអស់៩៣ហ្នឹង ។

វណ្ណៈ បោះឲ្យបក្សខាងណាចឹង?

រិទ្ធៈ បក្សប្រជាជន បោះឲ្យ ហ៊ុន សែន ។

វណ្ណៈ មិនមែនទេ?

រិទ្ធៈ មិនមែនម៉េច កាលនោះពួកខ្ញុំចុះហើយ ។

វណ្ណៈ បោះឲ្យខាង ហ៊ុន សែន ឬបោះឲ្យខាងហ៊្វុនស៊ិនប៉ិច?

រិទ្ធៈ អូរ!មិនមែនទេ ច្រឡំហើយ ខ្ញុំច្រឡំឆ្នាំ១៩៩៨ទេ ឆ្នាំ៩៣មិនបានបោះទេ ខ្ញុំច្រឡំទេ ឆ្នាំ៩៨បានបោះនោះ ។

វណ្ណៈ ចឹងបោះឆ្នោត៩៣?

រិទ្ធៈ បោះឆ្នោត៩៣ពួកខ្ញុំមិនបានបោះទេ ពួកខ្ញុំនៅខ្មែរក្រហម ហ្នឹងហើយមិនបានបោះទេមែន ។

វណ្ណៈ ចឹងដល់៩៨បានបោះ?

រិទ្ធៈ ចាស ។

វណ្ណៈ ចឹងឆ្នាំ៩៨យើងធ្វើសមាហរណ៍កម្មហើយ?

រិទ្ធៈ ហ្នឹងហើយសមាហរណ៍កម្មហើយ ។

វណ្ណៈ ចឹងមានសមាហរណ៍កម្មហើយយើងចុះចូលជាមួយរដ្ឋាភិបាល យើងបោះឲ្យខាងប្រជាជន?

រិទ្ធៈ ចាស!កាលហ្នឹងបោះដឹងណាណីទេ ប្ដីខ្ញុំអីហ្នឹង ប្ដីកាលហ្នឹងគេឲ្យដឹកសន្លឹកឆ្នោតមកគេបាញ់ឆេះអាត្រាក់ង៉ាប់អស់ពីរ ង៉ាប់អស់ពីរនាក់ ។

វណ្ណៈ ចឹង?

រិទ្ធៈ ចាស!ខាងតាម៉ុក បាញ់ តាម៉ុក មិនទាន់នេះ កាលហ្នឹងមួយប៉ែកខាងនេះចូលរដ្ឋាភិបាលប៉ែកខាងនោះគេអត់ចូលនោះ គេចាំស្ទាក់បាញ់ផ្លូវទៅអន្លង់វែងហ្នឹង ផ្លូវផ្ទះមេភូមិគេហៅយាយនឹម មានទួលមួយនៅជិតដល់ឡូណា ហ្នឹងគេបាញ់ឆេះអាត្រាក់ង៉ាប់អស់ពីរនាក់ ដឹកហិបឆ្នោតនៅអន្លង់វែង ។

វណ្ណៈ ចឹងមីងនៅឆ្នាំ១៩៩៨ហ្នឹង ខាងតាម៉ុក មិនចូលទៅខាងរដ្ឋាភិបាលទេ?

រិទ្ធៈ នៅទេ ។

វណ្ណៈ ចឹងនៅខាងនេះគេចូលមុន?

រិទ្ធៈ ចាស!ខាងខ្ញុំចូលមុន ។

វណ្ណៈៈ កាលហ្នឹងពីណាដឹកនាំចូល?

រិទ្ធៈ បងជុំ បងកែវ ហ្នឹង ។

វណ្ណៈៈ ហើយមីងរត់ទៅ?

រិទ្ធៈ ពួកខ្ញុំអត់ទៅ ពួកខ្ញុំអត់ទៅទេ គេឡើងភ្នំអស់ គេដឹកទៅឡើងភ្នំជាមួយតាម៉ុក ពួកខ្ញុំអត់ទៅ ។

វណ្ណៈៈ ចឹងនៅហ្នឹងមីងរត់ចូលទៅខាងនោះវិញ?

រិទ្ធៈ អត់ទេ នៅហ្នឹងតែម្តង ។

វណ្ណៈៈ ចឹងអត់មានរត់ផង?

រិទ្ធៈ ចាស!អត់រត់ ដល់នៅទៅមានអី បើទៅមានគ្រោះថ្នាក់ច្រើន គ្រោះថ្នាក់ត្រង់ថាបាត់បង់របស់របរចុះគោ អីយើងយកទៅថៃ ថៃឲ្យវាថោកៗ ខ្ញុំអត់ទៅ ខ្ញុំគិតថាគោស្រូវមានពេញជង្រុក ។

វណ្ណៈៈ ដល់ចឹងទៅអត់មានខាងណាមកឡុកឡុកមីងទេ?

រិទ្ធៈ មានដែរ មានខាងតាម៉ុក ហ្នឹងពួកខ្ញុំនៅអូរស្វាយ ចេញពីអូរស្វាយមកនៅហ្នឹង មកនៅហ្នឹងស្រូវអង្ករយើងនៅអូរស្វាយនោះ យើងបានតែគោ បានតែកូនអីមកចឹង ដល់ពេលទៅដឹកស្រូវយកមកហូប ទៅទាំងខ្លាចទាំងភ័យហ្នឹង ទៅចុចមីនតាមផ្លូវ យប់ឡើងបរទេះទៅ រទេះគោហ្នឹង ចុចមីនត្រូវរបួសពូមួយនៅជិតផ្សារ ខាងតាម៉ុក មកចុចមីនត្រូវរបួស ។

វណ្ណៈៈ ចឹងភូមិហ្នឹងកកើតតាំងពីឆ្នាំណាមក?

រិទ្ធៈ ភូមិហ្នឹងកើតមកតាំងពីពួកខ្ញុំចុះពីថៃមក តាំងពីឆ្នាំ៨៦-៨៧ហ្នឹងហើយ ។

វណ្ណៈៈ ដាក់ថាភូមិទួលពង្រហ្នឹង?

រិទ្ធៈ ភូមិទួលពង្រនេះ យើងទើបដាក់នៅពេលមានសមាហរណ៍កម្មហើយទេ ពីមុនមកគេហៅតាមអង្គភាព កាលតា០៥នៅ តែទំនប់ដាច់ដាក់តាំងពីគាត់នៅ ដាច់ទំនប់ដាច់ចឹង ។

វណ្ណៈៈ បាទ ។

រិទ្ធៈ តែភូមិនេះពីមុនគេហៅថាមន្ទីរ០៥ ពីមុនខ្ញុំនៅនោះទេ ។

វណ្ណៈៈ ចឹងមីងបើយើងធ្វើការប្រៀបធៀប កាលសម័យមីងតស៊ូមកដល់សម័យឥឡូវតើការរស់នៅមួយណាស្រួលជាង?

រិទ្ធៈ ខ្ញុំពិនិត្យទៅវារស់នៅដូចខ្ញុំនិយាយមិញចឹង រស់នៅមានសេរីភាពខ្ញុំអស់ចឹងបានជាងហ្នឹងទៀតហើយ ។

វណ្ណៈៈ បាទ!កូនចៅមានបាយហូប មានសាលារៀន មានពេទ្យ កូនចៅយើងអាចរៀនសូត្របាន?

រិទ្ធៈ ចាស!រៀនសូត្របាន ។
វណ្ណៈ ចឹងមីងគិតថា ក្មេងៗបានរៀនសូត្រតទៅមុខទៀត មីងគិតថាវាមានផលប្រយោជន៍អីដែរ?
រិទ្ធៈ មានផលប្រយោជន៍ច្រើនណាស់ ព្រោះអីខ្ញុំគិតថា ខ្ញុំអត់ចេះអក្សរ ខ្ញុំចេះតិចតួចចឹងដល់សង្គមឥឡូវត្រូវការអ្នកចេះដឹងចឹង ខ្ញុំគិតថាផលប្រយោជន៍របស់កូនវាមានច្រើន ព្រោះអីយើងមានសាលារៀន ម្យ៉ាងទៀតអង្គការដូចជាសាលារៀនចឹងមានអង្គការគាំទ្រចឹង គាត់ចុះមកជួយខាងអាហារូបករណ៍ឲ្យកូនក្មេងមានម្ដាយទីទាល់អីចឹង គាត់បានជួយឧបត្ថម្ភជាថវិការជាកង់ជាអីចឹង ឲ្យលុយមកទិញកង់សម្រាប់កូនរៀន ឃើញថាមានសារៈសំខាន់ច្រើនណាស់ សម័យនេះខុសមុនឆ្ងាយតែម្ដង ខ្ញុំនិយាយទៅវាមានអីត្រេកអរជាងសម័យនេះទៀតទេ ។
វណ្ណៈ ចឹងកូនមីងរៀនដល់ណាដែលរាល់ថ្ងៃហ្នឹង?
រិទ្ធៈ ឈប់រៀនអស់ហើយ ។
វណ្ណៈ ចឹងមានមូលហេតុអីបានជាគាត់ឈប់?
រិទ្ធៈ មីបងវារត់ចុះឡើងរៀនបានត្រឹមថ្នាក់ទី៤ ហើយមីប្អូននេះ កាលហ្នឹងផ្លូវវាអត់ទាន់មានរៀនសាលារៀននៅត្រពាំងប្រាសាទនោះ សាលារៀនយើងនេះមានត្រឹមបឋមណាស់ អនុរៀនត្រពាំងប្រាសាទ ដល់ចឹងគ្មានមធ្យោបាយវាឆ្ងាយដល់ចឹងវាឈប់រៀនទៅ ហើយយើងកាលហ្នឹងនៅខ្វះខាតដែរ កាលហ្នឹងមិនមានអីទិញសម្រាប់កូនជិះទៅរៀនអត់មានទេ ហើយដល់មកអាប្អូនវាតាមសម័យសង្គមទាញអត់បាន និស្ស័យវារៀនបានត្រឹមថ្នាក់ទី១០ ។
វណ្ណៈ ចឹងបានត្រឹមទី១០ដែរ?
រិទ្ធៈ ចាស ។
វណ្ណៈ ស្ដាយណាស់ រៀនឲ្យបានខ្ពស់មួយទៅ?
រិទ្ធៈ ឪពុកស្ដាយខ្លាំងណាស់ អត់មានអីស្មុងគាត់សោះ ឪពុករៀនបានត្រឹមថ្នាក់ទី៨“ចាស” តែគាត់អានបារាំងបានខ្លះ ជំនាន់ហ្នឹងរៀនបារាំង ដល់មកកូនវារៀនបានតិចចឹងគាត់ស្ដាយ គាត់ថាចឹង បើកូនចង់រៀនទោះអស់មានអីគាត់ខំ គាត់ជួយកូនឲ្យដល់ទីសដៅដែរ តែកូនវាទៅមិនរួចខ្លួនវាតែម្ដង វាឈប់ខ្លួនវា ។
វណ្ណៈ ចឹងជួយធ្វើការផ្ទះទៅ?
រិទ្ធៈ វាជួយជំនួយការស្មៀន ។
វណ្ណៈ ចឹង?
រិទ្ធៈ ចាស!អក្សរស្អាត ។
វណ្ណៈ ចឹងបានធ្វើការជាមួយដែរ?

រិទ្ធៈ ចាស ។

វណ្ណៈៈ ចឹងមីងរាល់ថ្ងៃមានតួនាទីអីដែរ?

រិទ្ធៈ ខ្ញុំសមាជិកក្រុមប្រឹក្សា ។

វណ្ណៈៈ ក្រុមប្រឹក្សាឃុំ?

រិទ្ធៈ ចាស!ខ្ញុំជាប់អាណត្តិនេះឯង ។

វណ្ណៈៈ ចឹងទាំងពូទាំងមីងធ្វើទាំងអស់គ្នា?

រិទ្ធៈ ចាស ។

វណ្ណៈៈ ចឹងមកដល់សព្វថ្ងៃនេះនៅភូមិហ្នឹងមានកើតវត្តបានប៉ុន្មានហើយ?

រិទ្ធៈ នៅទំនប់ដាច់ហ្នឹងមានតែវត្តមួយ ។

វណ្ណៈៈ ចឹងមានតែវត្តមួយ?

រិទ្ធៈ ចាស!វត្តនេះ ។

វណ្ណៈៈ កសាងយូរហើយនៅវត្តហ្នឹង?

រិទ្ធៈ វត្តហ្នឹងយូរដែលហើយធ្វើតាំងពីយើង៩០ប៉ុន្មានទេ វត្តហ្នឹងផ្តាច់ខ្លួនយូរដែលបានធ្វើ មានវត្តមួយតូចមានលោកមកពីក្នុងបានតែមួយអង្គ ចេះតែកសាងតិចៗទៅ ឥឡូវយើងកំពង់តែធ្វើវិហារ តែបានត្រឹមចាក់សរសរ ចាក់គ្រឹះបានសរសរប៉ុន្មានទេ ។

វណ្ណៈៈ ចឹងមីងរាល់ថ្ងៃហ្នឹងកាន់សាសនាអីដែរ?

រិទ្ធៈ ខ្ញុំកាន់សាសនាព្រះពុទ្ធហ្នឹងឯង នឹកឃើញកាន់សាសនាផ្សេងទៀតដូចជាសាសនាយេស៊ូអីធ្វើបុណ្យម្តាយឪពុកមិនបានចឹង ដឹងធ្វើយ៉ាងម៉េចកើតទេ អ្នកមានគុណ ខ្ញុំអត់មានទៅណាទេដដែល សាសនាយើង ។

វណ្ណៈៈ ចឹងមីងគិតថា ការគោរពសាសនាអីហ្នឹងទៅវត្តអីហ្នឹង តើមានផលប្រយោជន៍អីដែរ?

រិទ្ធៈ ខ្ញុំគិតថា យើងគោរពសាសនាផលប្រយោជន៍ បើនិយាយបុណ្យបាបវិញ ខ្ញុំមិនដឹងថាយ៉ាងម៉េចទេ ធ្វើទៅបានឬមិនបានដល់ឬមិនដល់អី អាហ្នឹងខ្ញុំមិនសូវនេះដែរ តែវាទំលាប់មនុស្សឲ្យចេះគោរពគ្នា ចេះខ្លាចបុណ្យបាបចឹងធ្វើឲ្យមនុស្សចេះគោរពគ្នា ចេះគោរពចាស់ទុំចឹងគោរពមិត្តភក្តិដូចជាបងជាប្អូនអីចឹង ក្នុងទស្សនៈរបស់ខ្ញុំគិតចឹង តែធ្វើដូចគេថា ចូលសរសរខ្ញុំនិយាយជាមួយលោក ដូចថាសង្ឃរាជវត្តនិយាយចឹង កាណាធ្វើនេះដឹងដល់មិនដល់បានមិនបាន កាណាមិនដឹងទេ តែគ្រាន់កាណាធ្វើទៅ ដើម្បីនិយាយរួមចាស់ៗថា យើងចេះធ្វើបុណ្យធ្វើទានដែលទៅ ទោះបីយើងមិនបានក៏គេសរសើរយើងដែរ ខ្ញុំគិតចឹងជាកំនិតរបស់ខ្ញុំ ។

វណ្ណៈ  ចឹងមីងដូចថានៅក្នុងស្រុកភូមិយើងហ្នឹងដូចថា  អ្នកជិតខាងអីបងប្អូនអីមីងរាប់អានយ៉ាងម៉េចដែរ?

រិទ្ធៈ  ខ្ញុំនៅនេះរាល់ថ្ងៃបើនិយាយបងប្អូនមានតែម្នាក់ទេ  បងប្អូនបង្កើតស្មុទ្ធតែញាតិដទៃទាំងអស់តែខ្ញុំមានពេលវេល វេលដូចជាការកូនបុធ្វើបុណ្យអីមួយខ្ញុំអត់មានពិបាកទេ ។

វណ្ណៈ  បាទ ។

រិទ្ធៈ  ចាស!ញាតិជួយខ្ញុំណាស់ គេគោរពខ្ញុំ និយាយទៅគេគោរពខ្ញុំតែម្ដង ជួយខ្ញុំអត់មានអីទេ ដូចខ្ញុំការកូន ត្រូវធ្វើចេះៗគ្រាន់តែប្រគល់ឲ្យគេ គេធ្វើឲ្យមួយចប់ខ្ញុំមិនដែលពិបាកទេ ខ្ញុំមិនដែលហត់ទេ ។

វណ្ណៈ  បាទ ។

រិទ្ធៈ  គ្រាន់យើងគិតថា ឲ្យតែរកប្រាប់ថាថ្ងៃនេះជួយវិចនំ ការកូនគេមកគ្រប់អត់មានពិបាកសោះសូម្បីតែចុងភៅខ្ញុំនិយាយចុងភៅចុះ គេគិតថា មួយតុគេយក៨០០០រៀល តែសម្រាប់ខ្ញុំអត់ទេ ការកូនបើគេយក៨០០០គេយកខ្ញុំតែ៦០០០បុក៏៧០០០អីហ្នឹង គេជួយខ្ញុំចឹង ។

វណ្ណៈ  បាទ ។

រិទ្ធៈ  ដល់ពេលឃើញចឹង ខ្ញុំគិតថាគេគោរពខ្ញុំ គិតថាខ្ញុំវាមនុស្សមួយដែរ បានគេចូលចិត្ត មិនថាចាស់ថាក្មេងទេ ពេលវេនបុណ្យ ពេលភ្ជុំបិណ្យចឹង ពេលវេនភូមិខ្ញុំចឹង គឺមានចាស់ៗមកច្រើនតែម្ដង ព្រោះអីខ្ញុំទម្លាប់ចាស់ៗម្ដាយឪពុកយើងស្លាប់អស់ហើយ ពេលបុណ្យវេដូវភ្ជុំអីចឹងខ្ញុំទិញជាមីបុជាទឹកក្រូចទឹកផ្លែឈើចឹងទៅ ខ្ញុំជូនគាត់ម្នាក់១០០០ទឹកផ្លែឈើមួយកំប៉ុងអីចឹង ដល់ចឹងគ្រាន់ថាស្អែកចូលវេនខ្ញុំចឹង ខ្ញុំលើកដៃសំពះគាត់អញ្ជើញគាត់ចាស់ៗមកច្រើនតែម្ដង ។

វណ្ណៈ  បាទ ។

រិទ្ធៈ  ពេលខ្ញុំមានវេលខ្ញុំសូត្រមន្តវិញមានមនុស្សពេញផ្ទះតែម្ដង ។

វណ្ណៈ  ចឹងការរាប់អានគ្នាមានលក្ខណៈល្អ?

រិទ្ធៈ  ចាស!មានលក្ខណៈល្អ ។

វណ្ណៈ  ចឹងចំពោះគ្រួសារកូនចៅអី មានទំនាក់ទំនងយ៉ាងម៉េចដែរ?

រិទ្ធៈ  ខ្ញុំនិយាយត្រង់ បើប្ដីខ្ញុំវិញ តាំងពីយកគ្នាមកដល់ចំណាស់នេះ មិនដែលប្ដីខ្ញុំហៅខ្ញុំមីបុងែងអត់មានទេ និយាយខ្ញុំ បើខ្ញុំហៅគាត់ឆ្លើយបាទបុខ្ញុំតែម្ដង និយាយទៅគោរពសិទ្ធគ្នាទៅវិញទៅមកប្ដីប្រពន្ធ តែកូនមិនបានធ្វើដូចបំណងមានមាត់កខ្វះដែរ ។

វណ្ណៈ  បាទ!ធម្មតាទេ?

រិទ្ធ:		ចាស ។

វណ្ណៈ:	ម៉ែឪប្រដៅចង់ឲ្យកូនល្អ?

រិទ្ធ:		ចាស!ណាមួយឃើញកូនគេល្អ ក្នុងចិត្តខ្លួនឯងវាមិនដូចបំណង កូនគេខ្លះគេមេម៉ាយគេគ្រប់គ្រងកូនគេបាន យើងមានប្ដីមានប្រពន្ធហើយយើងគ្រប់គ្រងកូនអត់បាន កូនដូចខ្ញុំនិយាយមិញចឹង ចង់ឲ្យវារៀនបានចប់ ចឹងរៀនអត់ចប់មានអារម្មណ៍មួយសោកស្ដាយហើយ មានអារម្មណ៍គិតថាមនុស្សគេមួយដែរ ឲ្យកូនរៀនមិនបានចប់ មិនដែលប្រើចឹងណា តែការពិតខ្លួនវា យើងជាម្ដាយបានត្រឹមខត្ដម្ភវា កែនិស្ស័យវាទៅមិនរួចដែរ ។

វណ្ណៈ:	ចឹងមីងក្នុងមួយឆ្នាំៗ មីងជាមួយគ្រួសារជាមួយកូនចៅមានដែលពិភាក្សាថា ឥឡូវកូនឬគ្រួសារថា ឆ្នាំនេះយើងត្រូវធ្វើអី ចង់ដាំអី ឆ្នាំនេះចង់ធ្វើអី ចឹងការងារបែបហ្នឹងមានដែលពិភាក្សាទេ ការងារទាំងអស់ហ្នឹង?

រិទ្ធ:		យើងពិភាក្សា បើនៅក្នុងក្រុមគ្រួសារយើងមិនពិភាក្សាយើងម៉េចទៅរួច ឧទាហរណ៍ថា ឆ្នាំក្រោយយើងត្រូវស្ទូងប៉ុន្មានហាត់ ស្ទូងមួយហាត់ចឹងទៅ ហើយយើងព្រោះប៉ុន្មាន ដូចថាកូនធ្វើដំឡូងធ្វើស្រែហើយ កូននិយាយរួមទៅខ្ញុំជួយទាំងអស់ ។

វណ្ណៈ:	បាទ ។

រិទ្ធ:		ពេលវាខ្វះខាត ពេលធ្វើដំឡូងអីវាខ្វះខាតខ្ញុំជួយកូនចឹងទៅ នៅកូនមួយមិនទាន់បានផ្ទះ អត់ទាន់បានផ្ទះនៅចឹងហើយចេះតែប្រឹងប្រែង កូនខ្ញុំផ្ទះខាងនោះហ្នឹងកូនច្បងហើយ អានេះក្មួយយកវាមកនៅជាមួយ ផ្ទះទល់មុខសាលាឃុំហ្នឹង អាហ្នឹងមីងបង បានមីងហ្នឹងមួយជួយទិញដែកមកចាក់សរសរដល់ពេលដំបូលខ្វះលុយខ្ញុំជួយវាបាន៥០០ដែរ ជួយកូនហើយរាល់ថ្ងៃកូនប្រុសរកបាន ខ្ញុំរាល់ថ្ងៃបើនិយាយរឿងកូនវិញខ្ញុំជាម្ដាយមួយល្អហើយ កូនខ្វះខាតអត់មានទៅណាទេ ហើយម្យ៉ាងទៀតគិតថាខ្លួនឯងវាចាស់ៗហើយ ចេះជួយផ្ដល់កូនណាដែលទាបជាងគេចេះតែជួយកូន ខ្ញុំមានគំនិតឲ្យកូនបានស្មើៗគ្នាចុះ តែកូនដឹងមិនដឹងកូនចេះមិនចេះមានគុណយ៉ាងម៉េចយើងមិនគិតទេ ព្រោះគិតថាតួនាទីរបស់យើងវាចិញ្ចឹមកូន មើលការខុសត្រូវកូនចឹង ហើយមានដែលគំនិតឲ្យកូនធ្វើដីមាន ដីស្រែក៏មានដីចម្ការក៏មាន កាលហ្នឹងខ្ញុំបានទិញដីបានច្រើនដែរ ព្រោះកាលដំនាន់គេចែកដី ខ្ញុំចាប់បានមួយចំនួនចឹង ពេលគេលក់ដំនាន់យើងដីបានថ្លៃហ្នឹង ខ្ញុំមិនបានលក់ដីហ្នឹងគេទេ ខ្ញុំមានតែទិញដីគេ ទិញដីស្រែហ្នឹងបាន៨ហាត់ឲ្យមីបង៥ហាត់ ខ្ញុំទុក៣ហាត់ ហើយអាហាត់ហ្នឹងចែកពីរនាក់ហ្នឹងមួយហាត់ម្នាក់ៗទៀត អាដីចាស់ចែកគ្នារួចហើយ ហើយដីចម្ការខ្ញុំទិញបាន១៨ហាត់ ដល់ចឹងឲ្យកូនមីមួយនេះមិនទាន់

បានផុះហ្នឹងឲ្យធ្វើដំឡូង ហើយខុះខាតប្រេង ខុះខាតថ្នាំ ខុះខាតជីអីហ្នឹង យើងចេះជួយតក់ៗចឹងទៅ ។

វណ្ណៈ៖ ចឹងបញ្ហាដីធ្លីទាំងអស់ហ្នឹងមានប៉ះពាល់ជាមួយក្រុមហ៊ុនឬយ៉ាងម៉េចដែរ មានគេមកជួយធ្វើប័ណ្ណអីឲ្យឬទៅ?

រិទ្ធៈ ទេ ព្រោះអីដីនៅទំនប់ដាច់នេះអត់មានទេ មានប្រជាជននៅទំនប់ដាច់ប្រហែលជា២០គ្រួសារដាងដែរ តែដីនៅក្នុងឃុំបាក់អន្លង់ ដីនៅបាក់អន្លង់ប៉ះដីក្រុមហ៊ុន ប្រជាជននៅទំនប់ដាច់តែមានដីនៅក្នុងឃុំបាក់អន្លង់ចឹង ។

វណ្ណៈ៖ ចឹងនៅក្នុងឃុំផ្សេង?

រិទ្ធៈ ចាស!មានប៉ះពាល់ចឹងដែរ តែដីខ្ញុំបើប៉ះ ប៉ះដីទាហាន ទាហានហ្នឹងមិនដឹងជាយ៉ាងម៉េចទេ ពួកវរសេនាធំទាហាន៨១នោះគេ បន្ទាយនៅខាងបាក់អន្លង់ចឹង តែមិនទាន់ដឹងទេ ហេតុផលគ្រាន់ឃើញថា ឆ្នាំមុនឃើញមកបាញ់ថ្នាំ ឥឡូវស្ងាត់វិញចឹង បើដីក្រុមហ៊ុនអត់មានប៉ះទេ បើប៉ះដីទាហាន ។

វណ្ណៈ៖ ចឹងមីងសង្ឃឹមថា ដីហ្នឹងមិនបាត់បង់ឬបាត់បង់?

រិទ្ធៈ ដីខ្ញុំបើបាត់បង់វាបាត់បង់មួយចំណែកហើយ ទាហានយកគេភ្ជួរអាត្រាក់តែខ្ញុំអត់និយាយទេអាហ្នឹង ។

វណ្ណៈ៖ តែបើមានខាងនិសិត្សគេមកធ្វើប្លង់មីងអាចប្រាប់គេ ប្រាប់ហេតុផលគេថាយើងមានភស្តុតាងចេះៗគេអាចធ្វើឲ្យយើង គេអាចវាស់ឲ្យយើងដែលតើ?

រិទ្ធៈ បើដីចម្ការនេះវាមិនទាន់មានអីខ្ញុំអាចធ្វើបាន តែដីទាហានហ្នឹងភ្ជួរអាត្រាក់ ភ្ជួរហើយអស់ដីកូនខ្ញុំ ដីខ្ញុំ ដីប្អូនខ្ញុំ ដីអ្នកជិតខាងច្រើនដែរ ទាហានយកទាំងអស់ ។

វណ្ណៈ៖ ចឹងយើងអត់មានតវ៉ាទេ?

រិទ្ធៈ តវ៉ាអត់បាន ប្រជាជនធ្វើហើយចឹង ប្រជាជនភូមិទួលចារគាត់ធ្វើចឹងរាល់ឆ្នាំច្រាំងស្រូវគេនៅរាល់ឆ្នាំចឹង ទាហានយកទាំងអស់ តែឥឡូវហ្នឹងមួយចំណែកប្រជាជននៅតែធ្វើ គាត់នៅតែធ្វើចឹង ។

វណ្ណៈ៖ ចឹងដោយសារមានគោលការណ៍ថាឲ្យដីប្រជាជនវិញ គេយកវិញបាន?

រិទ្ធៈ ចាស ។

វណ្ណៈ៖ ចឹងមានខាងក្រុមនិសិត្សគេមកវាស់ឲ្យ?

រិទ្ធៈ ចាស!ឥឡូវចេះ ឥឡូវមានដីជាប់ទំនប់ដាច់ដែរ ខាងអូរឫស្សីដីប្រជាជនធ្វើរាល់ឆ្នាំឥឡូវខាងប៉ូលីសគេយក កំពង់តែដោះស្រាយ ដីកាលហ្នឹងដីនៅក្នុងឃុំអូរស្វាយ ដីហ្នឹងដីទំនប់ដាច់តែអូរ

ស្វាយគេមកយកដល់អូរឫស្សីចិន ដល់ពេលក្រោយមកស្រុកបែកព្រំប្រទល់មួយសារទៀតដី ហ្នឹងមកនៅទំនប់ដាច់វិញ តែមេឃុំខាងអូរស្វាយគាត់បានប្រគល់ដីហ្នឹងឲ្យទៅប៉ូលីសព្រំដែនចិន ឥឡូវប៉ូលីសព្រំដែនគាត់យក ឥឡូវកំពង់តែតវ៉ា ។

វណ្ណៈ: ចិនមានការពាក់ព័ន្ធទៅលើបញ្ហាទាំងអស់ហ្នឹង តើមីងអាចទុកចិត្តទៅលើប្រព័ន្ធច្បាប់របស់ យើងរាល់ថ្ងៃហ្នឹងទេ បើសិនជាមានរឿងរ៉ាវនៅក្នុងភូមិ កូនចៅមានបញ្ហាអី មីងអាចពឹងពាក់ ច្បាប់បានទេ មីងគិតថាច្បាប់យើងរាល់ថ្ងៃហ្នឹងល្អឬមិនទាន់ល្អ?

រិទ្ធៈ: ខ្ញុំបើនិយាយរឿងច្បាប់វិញ ខ្ញុំមិនទុកចិត្តតែម្ដង ខ្ញុំនិយាយត្រង់ ព្រោះអីកន្លងទៅដូចថាមាន បញ្ហារឿងដីចិន និយាយជាមួយស្រុកចិន ខាងស្រុកគាត់ថា សម្ដេចគាត់បែកមួយចំហៀងឲ្យ ទៅទាហានចិន ឲ្យទាហានគ្រប់គ្រងចិន ចិនគេមានប្រថាប់ត្រាពីសម្ដេចអីចិនមក ខាងស្រុក គាត់ក៏មិនហ៊ាន ដល់ចិនដីវាមានការបាត់បង់ដីខ្ញុំមួយចំនួនកន្លងទៅទាហានយកហ្នឹង ដល់ចេះពី សម្ដេចមកចិនរកនិយាយមិនកើត ។

វណ្ណៈ: យើងមិនដឹងថា លិខិតចេញមកពីសម្ដេចចេញមកពិតប្រាកដឬមួយយ៉ាងម៉េច ទោះបីក្លែង ក្លាយក៏យើងមិនដឹងទៀត?

រិទ្ធៈ: ចាស! យើងមិនដឹងទៀត ។

វណ្ណៈ: យើងជាប្រជាជនយើងម៉េចហ៊ានតវ៉ាអី?

រិទ្ធៈ: ចាស!ដល់ខ្ញុំរាយការណ៍ឲ្យស្រុកម្ដងហើយម្ដងទៀត ដូចថាវាមិនមានប្រសិទ្ធភាពអីទៀតផង ស្រុកក៏គាត់មិនហ៊ាននិយាយតទៅវិញ ខ្ញុំនិយាយស្មោះត្រង់ ច្បាប់វាមានចិនដែរ សម្រាប់ អ្នកធំអ្នកតូចចិន វាមិនទាន់ត្រឹមត្រូវដែរ កន្លងមកស្រុកអត់ហ៊ានចិន បើនិយាយដីជាមួយ ក្រុមហ៊ុន យើងដោះស្រាយស្រួលទៅវិញ តែជាមួយទាហានគឺយ៉ាប់តែម្ដង ចិនបានខ្ញុំថាបើ សម្ដេចនៅគិតដល់ទាហានជាងប្រជាជនយ៉ាប់ដែលហ្នឹង យ៉ាប់រឿងគ្រប់គ្រងកម្លាំងនិយាយរួម ទៅការដឹកនាំខាងក្រោមៗឃុំមូលដ្ឋានអីយ៉ាប់ដែរ ។

វណ្ណៈ: បាទ ។

រិទ្ធៈ: ប្រជាជនគាត់ខំប្រឹងធ្វើ បើដីព្រៃតែម្ដងវាមិនសូវអីទេ ។

វណ្ណៈ: ចិនដីប្រជាជនធ្វើហើយ?

រិទ្ធៈ: ចាស!ប្រជាជនធ្វើហើយ នៅមានដោះស្រាយមិនចេញចិនយ៉ាប់ ។

វណ្ណៈ: ចិនមីងនៅក្នុងស្រុកភូមិយើងអត់ទាន់មានក្រុមហ៊ុនមកវិនិយោគទន់ធ្វើ ដូចជាខស្សរាហ៍កម្មកាត់ ដេរឬមានរោងចក្រអីធំៗ អត់ទាន់មានទេនៅក្នុងភូមិឃុំយើងហ្នឹង?

រិទ្ធៈ: អត់ទាន់មានទេ ។

វណ្ណៈ៖ ចឹងមីងចង់ឲ្យមានក្រុមហ៊ុនមកធ្វើការវិនិយោគនៅក្នុងស្រុកយើងទេ?

រិទ្ធៈ ចង់ ។

វណ្ណៈ៖ ដើម្បីឲ្យកូនចៅមានការងារធ្វើ?

រិទ្ធៈ ចាស!ចង់ឲ្យកូនចៅមានការងារធ្វើមិនចង់ឲ្យទៅធ្វើឆ្ងាយ កូនចៅខ្ញុំមិនទៅណាទេ តែបងប្អូនជិតខាងកូនធំៗហើយគ្នាខ្លះខាតអីចឹង បើមានក្រុមហ៊ុនធំៗចុះមកចឹងវាស្រួលងាយបំផុតដែរចឹងណាស់ ។

វណ្ណៈ៖ ចឹងផលដំណាំដំឡូង សណ្តែក ពោត ដែលធ្វើបានហ្នឹងដូចថាមានទីផ្សារដែលពេលធ្វើបាន?

រិទ្ធៈ ពោត សណ្តែក ដំឡូងអី អត់មានអីទេ មានឡានគេមកទិញចឹងវាមិនអីទេ ឲ្យតែយើងធ្វើបាន អាហ្នឹងអត់មានបញ្ហាទេ តែគ្រាន់បេះរបស់កសិករយើងវានៅមានកំរិតទាបដែរ ។

វណ្ណៈ៖ បាទ ។

រិទ្ធៈ ឧទាហរណ៍ស្រូវចឹង យើងប្រើជីប៉ុក៏របើថ្នាំបាញ់ស្មៅអីទៅ យើងទូទាត់ទៅវាមិនចំនិញប៉ុន្មានដែរ ដូនកាលបានត្រឹមម៉ាទប់ តែមានដីខ្លះដីល្អ ដូចដីខ្ញុំមិនទាន់មានប្រើអីទេ តែមានបងប្អូនខ្លះមានដីមិនសូវល្អចឹង យើងត្រូវប្រើជីថែមចឹង យើងទូទាត់ទៅទំនិញទីផ្សារវាខ្ពស់ ទំនិញកសិករយើងវាថោក មានតម្លៃទាប ។

វណ្ណៈ៖ ចឹងនៅមានផលប៉ះពាល់ដែរ?

រិទ្ធៈ ចាស!ស្រូវបានមួយគីឡូត្រឹម៨០០រៀលយើងគិតមើល ហើយបងប្អូនចិញ្ចឹមជ្រូកកន្លកមួយគីឡូមួយពាន់ហើយស្រូវបានតែមួយគីឡូ៨០០ ។

វណ្ណៈ៖ ចឹងយើងចិញ្ចឹមពិបាកចំនិញដែរ?

រិទ្ធៈ ចាស!ពិបាកចំនិញដែរ កាលពីម្សិញមិញខ្ញុំទៅប្រជុំនៅខាងស្រុកអន្លង់វែង គេធ្វើនិវារគេយើងសរសេរដាក់យើងប្រឈមនិងបញ្ហាអីខ្លះ ។

វណ្ណៈ៖ ចឹងយើងសរសេរទៅដើម្បីគេបានដឹង?

រិទ្ធៈ ចាស!ខ្ញុំសរសេរដែលហ្នឹង ខ្ញុំសរសេរទិន្នផលស្រូវអីចឹងវានៅទាប ចង់ឲ្យមានទីផ្សារខ្ពស់អីចឹងខ្ញុំសរសេរដាក់ចឹង ។

វណ្ណៈ៖ យើងសរសេរឲ្យដឹងថាឥឡូវជីអីថ្លៃហើយផលដែលយើងធ្វើបានទប់មិនជាប់ ចឹងយើងមានបញ្ហាអីខ្លះ នៅក្នុងស្រុកភូមិបើគេមានប្រជុំចឹង យើងត្រូវសរសេរឲ្យដឹងដើម្បីឲ្យថ្នាក់លើនោះគេបានដឹងដែរ?

រិទ្ធៈ ចាស! តែចៅហ្វាយខេត្តគាត់ថា នៅជាងហាសិបក្រដាសយើងសរសេរអាហ្នឹងគាត់មិនអានទេ គាត់យកទៅពិចារណាបន្តទៀត អាហ្នឹងច្រើនមានបញ្ហាធ្ងន់ៗណាស់ ខ្ញុំសររសរមួយដែលបញ្ហាហ្នឹង អាហ្នឹងខ្ញុំមិនបានដាក់ឈ្មោះខ្ញុំទេ ។

វណ្ណៈ៖ ចឹងបញ្ហាប្រជុំចឹង ទើបតែមានពេលឥឡូវនេះរឿងបញ្ហាឲ្យយើងរិះគន់ឬមួយពីមុនមកឲ្យយើងរិះគន់ដែរ?

រិទ្ធៈ អត់ទេ ពីមុនមិនមានទេ ទើបមានឥឡូវហ្នឹងដែរ ។

វណ្ណៈ៖ ចឹងប្រហែលជារដ្ឋាភិបាលចង់កែទម្រង់ ចង់ដឹងរឿងពីថ្នាក់ក្រោម?

រិទ្ធៈ ចាស ។

វណ្ណៈ៖ ពីព្រោះឥឡូវប្រជាជនហាក់ដូចជាផុសផល ផុសផលត្រង់ថាពួកគាត់ងើបឈរតវ៉ាឥឡូវមានការតវ៉ាច្រើនណាស់ ចឹងថ្ងៃក្រោយបើសិនជាគណៈប្រជាជនធ្វើអីមិនល្អអាចមានបញ្ហាទៅថ្ងៃក្រោយទៀត ។

រិទ្ធៈ ចាស ។

វណ្ណៈ៖ ចឹងបានជាខាងរដ្ឋាភិបាលគេចង់ដឹងចិត្តប្រជាជនគាត់ត្រូវការអីខ្លះ ចឹងទើបមានថ្មីៗទេ?

រិទ្ធៈ ចាស! ខាងឃុំខ្ញុំទើបធ្វើបានមួយដង ហើយទៅខាងខេត្តចុះមកម្សិលមិញហ្នឹងធ្វើបានម្តង តែស្រុកមិនទាន់បានដែលធ្វើទេ តែខ្ញុំនៅចេះដែរ បើធ្វើទិវាការរិះគន់ចឹង បើឲ្យអ្នកសរសេរដាក់ឈ្មោះ គ្នាមិនហ៊ានដាក់ទេ ។

វណ្ណៈ៖ បាទ! ត្រូវហើយ ។

រិទ្ធៈ ព្រោះអីខ្ញុំសរសេរម្សិលមិញមួយ ខ្ញុំសរសេរបានបីសន្លឹក មួយសន្លឹកខ្ញុំសរសេរមិនបានដាក់ឈ្មោះខ្ញុំទេ អាហ្នឹងខ្ញុំសរសេររឿងបញ្ហាដីធ្លីដែរ ដូចខ្ញុំនិយាយមិញចឹង បើនិយាយពីទិន្នផលស្រូវហ្នឹងខ្ញុំនិយាយដាក់ឈ្មោះខ្ញុំ ព្រោះគេឲ្យសរសេរដាក់ឈ្មោះយើងអ្នកសរសេរ ដល់ចឹងភាគច្រើនមិនហ៊ានសរសេរ បញ្ហាឃើញតែមិនហ៊ានសរសេរ បើសរសេរទៅខ្លាចគេហៅទៅសួរនាំ នាំតែវ៉ែនកខ្លួនឯងទេ មិនបាច់សរសេរមិនបាច់ដាក់ បញ្ហាចឹងៗអី ចឹងខ្ញុំថារកដំណោះស្រាយមិនឃើញទេ សរសេរទៅ ដូចជាបញ្ហាកុងត្រូជជុះអីហ្នឹង គេប្រាប់មេភូមិមេឃុំទៅដែរ ខ្ញុំថាក្នុងភូមិយើងមានហេតុផលហ្នឹងហើយយើងសរសេរទៅភូមិខ្ញុំមានកុងត្រូជជុះ យើងបានស្តាប់សម្តេចហើយយើងមិនមានកុងត្រូជជុះណាស់ ដូចថាដាក់យកលុយគេចាយមកដឹកស៊ីអីចឹង ហើយមកនៅម្នាក់មកចាំយក ដល់ចឹងយើងសរសេរទៅ យើងរិះគន់ដើម្បីឲ្យគាត់កែប្រែ ខ្លះមិនហ៊ានសរសេរ ។

វណ្ណៈ ចឹងខ្ញុំចង់សួរមីងបន្តបន្តិចទៀតចប់ហើយ បើសិនជាមានជនជាតិផ្សេង ដូចជាថៃ-យួន អីមក ទិញដីរស់នៅក្បែរយើងចឹង ក្នុងចិត្តមីងសប្បាយចិត្តទេ?

រិទ្ធៈ និយាយច្បាប់មានតែម្តង អត់មានឲ្យលក់ចេញក្រៅ ទោះយើងធ្វើប្លង់ដីចឹងលក់គេយកអត្ត សញ្ញាណបណ្ណមក បើជនជាតិបរទេសមិនឲ្យយើងលក់ ។

វណ្ណៈ បាទ! ត្រូវហើយមិនឲ្យលក់ទេ ។

រិទ្ធៈ ចាស ។

វណ្ណៈ ចឹងបើសិនជាពួកហ្នឹងមកនៅជាលក្ខណៈជួលមកនៅជិតយើងចឹង អារម្មណ៍យើងសប្បាយចិត្ត ទេ បើមិនមែនជាជនជាតិយើងចឹង?

រិទ្ធៈ ទោះបីឧទាហរណ៍យើងពិនិត្យទៅ ទោះបីយើងម្នាក់ថាឲ្យនៅចឹង ពួកខាងសិប្បកម្មអីចឹង និយាយរួមនៅវាប៉ះពាល់នយោបាយយើង ព្រោះគេមិនពេញចិត្ត និយាយបាយប្រឆាំងគេ ថាយើងយកជនជាតិបរទេសមកនៅក្នុងឃុំនៅក្នុងទឹកដីចឹង គេមិនគាំទ្រទេ និយាយទៅយើង មិនគាំទ្របានទេ ព្រោះអីយើងតម្រូវការប្រជាជន ។

វណ្ណៈ ចឹងបើខ្មែរគ្នាឯងមិនអីទេ?

រិទ្ធៈ អត់អីទេ ខ្មែរគ្នាឯងមិនអីទេ គ្មានបញ្ហាអីទេ ។

វណ្ណៈ ចឹងចង់និយាយពីទំលាមទំលាប់ខ្មែរយើងពីដើមមានប្រពៃណីគោរពចាស់ទុំ មានការស្លៀកពាក់ អីមកនៅសម័យកាលនេះ តើការស្លៀកពាក់ឥឡូវហ្នឹងពីដើមខុសគ្នាឬមួយដូចគ្នាដូចសម័យ មុនបើតាមមីងដឹង?

រិទ្ធៈ តាមខ្ញុំដឹងអត់ដូចទេ ព្រោះអីឥឡូវសូម្បីទៅវត្ត ពីដើមគាត់ស្លៀកសំពត់អាស៊ីបបត់អាវបាក់ ចឹងទៅវត្ត តែឥឡូវឃើញសំពត់ត្រឹមៗនេះ ហើយខោកាប៊ូញតឹងចង់បត់ជើងសំពះលោកមិន កើតផងវាតឹង ចឹងទំលាមទំលាប់ប្រពៃណីវាបាត់បង់ អត់មានតាមទំលាមទំលាបប្រពៃណីខ្មែរ យើងកាលពីបុរាណអត់មានទេ ភាគច្រើនអត់មានតែម្តង ។

វណ្ណៈ ចឹងមានន័យថាប្រែក្លាយ?

រិទ្ធៈ ចាស! ពីមុនមានតែតាមទីក្រុងធំៗចឹង តាមភ្នំពេញ តាមខេត្តសៀមរាប កំពង់ចាម កំពង់ធំ អីចឹងទៅ តែឥឡូវឈានចូលមកដល់ជនបទ កូនខ្ញុំអីសុទ្ធតែចឹងឯង សុទ្ធតែសំពត់ត្រឹមៗហ្នឹង ហើយទៅវត្តស្លៀកសំពត់បទជើងមិនកើត ទំលាមទំលាបប្រពៃណីខ្មែរវាអស់ត្រឹមហ្នឹង បាត់ បង់ច្រើន ។

វណ្ណៈ ចឹងខ្ញុំដូចជាអត់មានអីសួរមីងទៅទេ មីងមានអីចង់បន្ថែមទៀតទេ?

រិទ្ធៈ ខ្ញុំអត់មានអីទេ បានមកសួរខ្ញុំ ខ្ញុំអរគុណច្រើន ។

វណ្ណៈ	បាទ ។

រិទ្ធៈ	បានដឹងរឿងរ៉ាវច្រើន ក្នុងឃុំខ្ញុំ ដូចជារឿងខ្ញុំផ្ទាល់ ។

វណ្ណៈ	ខ្ញុំក៏អរគុណមីងច្រើនហើយដែលបានផ្ដល់បទសម្ភាសឲ្យខ្ញុំជាងមួយម៉ោងនេះ ចឹងអរគុណច្រើនមីងណាស់ ។

រិទ្ធៈ	ចាស ។

**ចប់**